**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ០៨ សរ

# សារាចរ
# ស្តីពី
# ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៤-២០២៦ និង ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤

## ១-សេចក្តីផ្តើម

១-ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ(ថ្មី) ត្រូវបានប្រកាសដាក់ឱ្យអនុវត្តដោយព្រះរាជក្រមលេខ នស/រកម/ ០៣២៣/០០១ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២៣។ អនុលោមតាមមាត្រា ៥១ នៃច្បាប់នេះ, ដោយផ្អែកលើក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងក្របខ័ណ្ឌថវិការយៈពេលមធ្យម ដែលរាជរដ្ឋាភិបាលបានកំណត់, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំសេចក្តីព្រាងសារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងសារាចរស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ *ជាសារាចររួមតែមួយ* ដើម្បីដាក់ជូននាយករដ្ឋមន្ត្រី ពិនិត្យ និងសម្រេច នៅដើមខែ ឧសភា។ ក៏ប៉ុន្តែ, អាស្រ័យដោយនៅក្នុងឆ្នាំ ២០២៣ នេះ ជាលើកទី ១ នៃការអនុវត្តច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ(ថ្មី) ដែលទើបចូលជាធរមាន, រាជរដ្ឋាភិបាលបានសម្រេចបន្តការរៀបចំ "**ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤**" មួយឆ្នាំនេះទៀតសិន និងបានសម្រេចពន្យារពេលដាក់ចេញនូវក្របខ័ណ្ឌនេះ មកក្នុងខែ មិថុនា ឆ្នាំ ២០២៣ ដោយសារ, ម្យ៉ាង, រង់ចាំ ការសម្រេចឱ្យប្រើប្រាស់ ផ.ស.ស. ឆ្នាំគោលថ្មី ឱ្យស្របនឹងការប្រែប្រួលរចនាសម្ព័ន្ធនៃស្ថានភាពសេដ្ឋកិច្ច និង, ម្យ៉ាងទៀត, សេដ្ឋកិច្ចសកលនៅក្នុងឆ្នាំ ២០២៣ មានភាពមិនប្រាកដប្រជាខ្ពស់ ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវការពេលវេលា និងព័ត៌មានបន្ថែម ក្នុងការព្យាករឡើងវិញលើក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ឱ្យបានស៊ីជម្រៅ និងសមស្របទៅនឹងការប្រែប្រួលជារចនាសម្ព័ន្ធនៃស្ថានភាពសេដ្ឋកិច្ចទាំងក្នុង និងក្រៅប្រទេស។ ហេតុដូច្នេះហើយ សេចក្តីព្រាងសារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤ ដែលត្រូវដាក់ចេញដើម្បីណែនាំដល់គ្រប់ក្រសួង-ស្ថាប័នអនុវត្ត ក៏ត្រូវបានពន្យារពេលរហូតមកដល់ពេលនេះដែរ។

២-ជាមួយនឹងការពន្យារពេលនូវការរៀបចំដូចបានជម្រាបជូនខាងលើ, ដោយសារការរៀបចំ ផ.ស.ស. ឆ្នាំគោលថ្មីនេះ, ជាបច្ចេកទេស, ត្រូវការពេលវេលាច្រើន និងមានវិសាលភាពធំធេងលើសពីការរំពឹងទុកដើម្បីធ្វើការកែតម្រូវវិធីសាស្ត្រឱ្យស្របតាមឧត្តមានុវត្តជាអន្តរជាតិ, រាជរដ្ឋាភិបាលបានសម្រេចអនុញ្ញាតឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រើប្រាស់ ផ.ស.ស. ឆ្នាំគោលចាស់សិនសម្រាប់ការរៀបចំក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៤។ ព្រមជាមួយគ្នានេះ, ក្រោយពីបានតាមដានប្រកបដោយ

ការយកចិត្តទុកដាក់នូវការវាយតម្លៃរបស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ អំពីផលប៉ះពាល់នៃការបន្តអូសបន្លាយនៃសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន មកលើស្ថានភាពសេដ្ឋកិច្ចសកល និងតំបន់, រាជរដ្ឋាភិបាលបានដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤ ហើយដែលក្របខ័ណ្ឌនេះត្រូវបានប្រើប្រាស់សម្រាប់ការចេញសារាចរណែនាំដល់គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារបានប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) រៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៤-២០២៦ និងការលើកគម្រោងថវិកាឆ្នាំ ២០២៤។

## ២-ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

៣-ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤ បានផ្តល់ទស្សនវិស័យរយៈពេលមធ្យមនៃការអភិវឌ្ឍសេដ្ឋកិច្ច និងកំណត់អាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល ព្រមទាំងនិន្នាការចំណូល និងចំណាយថវិកាជាតិសម្រាប់រយៈពេលមធ្យម ២០២៤-២០២៦ ក៏ដូចជាផ្តល់នូវលំហថវិការួមសម្រាប់ដោះស្រាយតម្រូវការចំណាយរបស់គ្រប់ក្រសួង-ស្ថាប័ន សម្រាប់រយៈពេលខ្លី និងមធ្យមរបស់ខ្លួន។ ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ក៏កំណត់ផងដែរអំពីលទ្ធភាពផ្នែកធនធាន និងអាទិភាពគោលនយោបាយចម្បងៗ ដើម្បីសម្រេចគោលដៅរួមរបស់រាជរដ្ឋាភិបាល។ ដូចនេះអាចនិយាយបានថា នៅក្នុងដំណើរការនៃការរៀបចំផែនការថវិកា ការកំណត់ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺជាយន្តការពីលើចុះក្រោម ចំណែកឯការរៀបចំផែនការយុទ្ធសាស្ត្រថវិកា គឺជាយន្តការពីក្រោមឡើងលើ។ យន្តការទាំងពីរនេះ គឺមានភាពចាំបាច់មិនអាចខ្វះបានដើម្បីធានាប្រសិទ្ធភាព និងភាពប្រាកដប្រជាអំពីលទ្ធភាពថវិកា និងការរៀបចំច្បាប់ថវិកាប្រចាំឆ្នាំ។

ខ្លឹមសារស្នូលនៃក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤ ត្រូវបានគូសរំលេចដូចខាងក្រោម៖

### ២.១-ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

៤-សេដ្ឋកិច្ចសកល ត្រូវបានព្យាករថាមានកំណើនយឺតក្នុងអត្រា ២,៨% សម្រាប់ឆ្នាំ ២០២៣ និង ៣,០% សម្រាប់ឆ្នាំ ២០២៤ ដែលជាកំណើនមួយទាបជាងអត្រាកំណើនជាមធ្យមប្រមាណ ៣,៨% ក្នុងរយៈពេល ២០ ឆ្នាំចុងក្រោយ។ កំណើនយឺតនេះ ឆ្លុះបញ្ចាំងពីការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ ដែលជាការឆ្លើយតបទៅនឹងការកើនឡើងនៃអតិផរណា ជាពិសេសនៅបណ្តាប្រទេសអភិវឌ្ឍន៍ និងផលប៉ះពាល់ពីសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន មកលើការផ្គត់ផ្គង់ និងថ្លៃថាមពល។ កំណើនយឺតក្នុងឆ្នាំ ២០២៣ ត្រូវបានទាញទម្លាក់ដោយកំណើនទាបជាងនិន្នាការធម្មតា នៅតាមបណ្តាប្រទេសអភិវឌ្ឍន៍ ក្នុងខណៈដែលកំណើននៅតាមបណ្តាក្រុមប្រទេសមានសេដ្ឋកិច្ចកំពុងរីកលូតលាស់ និងកំពុងអភិវឌ្ឍ នឹងមានការងើបឡើងវិញក្នុងឆ្នាំ ២០២៣ បន្ទាប់ពីសម្រេចបាននូវកំណើនយឺតក្នុងឆ្នាំ ២០២២។ សម្រាប់ឆ្នាំ ២០២៤ ក្រុមប្រទេសទាំងពីរ នឹងបន្តងើបឡើងវិញក្រោមការរំពឹងទុកនូវការថមថយនៃឥទ្ធិពលអវិជ្ជមានពីសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងការគ្រប់គ្រងបាននូវអតិផរណាជាសន្សឹមៗ។

ជារួម, សេដ្ឋកិច្ចសកល បាន និងកំពុងហ៊ុមព័ទ្ធដោយហានិភ័យ និងភាពមិនប្រាកដប្រជាមួយចំនួន ដែលនៅតែអាចបន្តយាយីមកលើការខិតខំប្រឹងប្រែងស្តារសេដ្ឋកិច្ចឡើងវិញរបស់ប្រទេសនានា រួមមាន៖ (១)-ការបន្ត

អូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ដែលបង្កជាបច្ច័យអវិជ្ជមានមកលើថ្លៃថាមពលលើទីផ្សារអន្តរជាតិ, (២)-ការកើនឡើងនូវភាពតានតឹងផ្នែកហិរញ្ញវត្ថុ, (៣)-ការកើនឡើងខ្ពស់នៃអតិផរណា, (៤)-ការបែងចែកភូមិសាស្ត្រនយោបាយ និង (៥)-ការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ ជាដើម។ ក្នុងន័យនេះ, ទិសដៅគោលនយោបាយជាសកល ត្រូវបានផ្តោតជាសំខាន់លើការកាត់បន្ថយសម្ពាធអតិផរណា, ការទប់ស្កាត់ការផ្ទុះឡើងវិញនៃជំងឺកូវីដ-១៩, ការធានាឱ្យបាននូវស្ថិរភាពហិរញ្ញវត្ថុ, ការធានានូវចីរភាពបំណុល និងការកសាងលំហហិរញ្ញវត្ថុឡើងវិញ, ការគាំទ្រដល់ក្រុមជនងាយរងគ្រោះ, ការពង្រឹងខ្សែច្រវាក់ផ្គត់ផ្គង់ និងការជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិ។

៥-សម្រាប់សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២៣ នេះ, ត្រូវបានវាយតម្លៃឡើងវិញថានឹងសម្រេចបាននូវកំណើនក្នុងរង្វង់ ៥,៦%, ដូចគ្នានឹងការព្យាករកាលពីដើមឆ្នាំ, គឺខ្ពស់ជាងឆ្នាំ ២០២២ ដែលសម្រេចបាននូវកំណើតក្នុងអត្រា ៥,២% ប៉ុណ្ណោះ។ ការសម្រេចបាននូវអត្រាកំណើននេះ គឺបណ្តាលមកពីការថមថយកំណើននៃវិស័យកាត់ដេរដោយសារការថមថយនូវតម្រូវការសកល ជាពិសេសនៅប្រទេសជាដៃគូពាណិជ្ជកម្មរបស់កម្ពុជា រួមមានៈ សហរដ្ឋអាម៉េរិក និងសហភាពអឺរ៉ុប ក្នុងខណៈដែលវិស័យកម្មន្តសាលមិនមែនកាត់ដេរនៅបន្តរក្សាកំណើនល្អដូចការរំពឹងទុក ដោយសារសក្តានុពលខ្ពស់នៃសកម្មភាពផលិតកម្មបម្រើឱ្យការនាំចេញមួយចំនួន រួមមានៈ គ្រឿងបង្គុំសូឡា និងសំបកកង់ និងផលិតកម្មបម្រើឱ្យតម្រូវការក្នុងស្រុក ជាពិសេសផលិតកម្មចំណីអាហារ និងភេសជ្ជៈ និងឧស្សាហកម្មដំឡើងរថយន្ត ជាដើម។ ចំពោះវិស័យសំណង់ និងអចលនទ្រព្យ, វិស័យនេះនៅបន្តកំណើនវិជ្ជមានក៏ប៉ុន្តែមាននិន្នាការថមថយ ដោយសារការបន្តថមថយសកម្មភាពសំណង់ និងចរន្តទិញ-លក់លំនៅឋានថ្លៃខ្ពស់ ក៏ប៉ុន្តែ ត្រូវបានប៉ះប៉ូវដោយកំណើនសកម្មភាពសំណង់ និងចរន្តទិញ-លក់លំនៅឋានថ្លៃទាប និងសំណង់បម្រើឱ្យឧស្សាហកម្ម ព្រមទាំងសេវាកម្មក្នុងស្រុក រួមមាន សំណង់រោងចក្រ និងអគារផ្សារទំនើប និងផ្សារលក់រាយ ជាដើម។ ចំណែកវិស័យកសិកម្មវិញ គឺនៅបន្តរក្សាកំណើនវិជ្ជមាន ក៏ប៉ុន្តែមានកំណើនថមថយជាងការរំពឹងទុក ដោយសារការកើនឡើងទាបនៃអនុវិស័យដំណាំ ពិសេសស្រូវវស្សាដែលបណ្តាលមកពីកត្តាអាកាសធាតុ និងកំណើនថមថយនៃអនុវិស័យចិញ្ចឹមសត្វ ជាពិសេសផលិតកម្មជ្រូក ដោយសារកត្តាថ្លៃ និងការនាំចូលសាច់បង្កកពីក្រៅប្រទេស។

ជារួម, កំណើនសេដ្ឋកិច្ចកម្ពុជាសម្រាប់ឆ្នាំ ២០២៣ ត្រូវបានរួមចំណែកយ៉ាងសំខាន់ និងប៉ះប៉ូវមកវិញដោយសារការបន្តកើនឡើងខ្ពស់ជាងការរំពឹងទុកនៃអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន (វិស័យទេសចរណ៍) និង អនុវិស័យគាំទ្រផ្សេងទៀត រួមមានៈ អនុវិស័យដឹកជញ្ជូន និងអនុវិស័យលក់ដុំ-រាយ ជាដើម។ ការត្រឡប់មករកប្រក្រតីភាពវិញនៃសង្គម-សេដ្ឋកិច្ចសកល បានធ្វើឱ្យមានការបន្តកើនឡើងនៃរំហូរមនុស្សទាំងក្នុងកម្រិតសកល, តំបន់ និងកម្ពុជាខ្លួនឯង។ លើសពីនេះ, ជោគជ័យដ៏មហាអស្ចារ្យនៃការធ្វើជាម្ចាស់ក្នុងការរៀបចំកីឡាស៊ីហ្គេម ក៏បានក្លាយជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយរបស់កម្ពុជា ក្នុងការទាក់ទាញនូវទេសចរអន្តរជាតិទាំងសកល និងតំបន់មកកម្ពុជាបន្ថែមទៀត ទាំងក្នុងឆ្នាំនេះ ក៏ដូចជារយៈពេលខ្លី និងមធ្យមខាងមុខ។ ការបន្តកើនឡើងនូវទេសចរអន្តរជាតិ ក៏ផ្តល់ផលវិជ្ជមានមកលើសកម្មភាពប្រើប្រាស់ក្នុងស្រុក ក៏ដូចជាសេវាកម្មគាំទ្រផ្សេងទៀតផងដែរ។ ជាការពិត, ឥទ្ធិពលនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែនគួបផ្សំនឹងស្លាកស្នាមដែលសេសសល់ពីវិបត្តិជំងឺកូវីដ-១៩ ក៏បន្តបង្កជាផលប៉ះពាល់លើទិដ្ឋភាពសង្គម-សេដ្ឋកិច្ចរបស់កម្ពុជា ជាពិសេសក្រុមប្រជាជនងាយរងគ្រោះ។ ទោះជាយ៉ាងនេះក្តី, រាជរដ្ឋាភិបាល ក៏បាននិងកំពុងបន្តអនុវត្តវិធានការអន្តរាគមន៍ ជាពិសេសការដាក់ចេញនូវកញ្ចប់អន្តរាគមន៍សម្រាប់គ្រួសារងាយរងហានិភ័យ ដោយសារការកើនឡើងអតិផរណា ដែលនឹងជួយបន្ថយផលប៉ះពាល់លើជីវភាពប្រជាជន ក៏ដូចជាទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ចសម្រាប់ឆ្នាំ ២០២៣ ផងដែរ។

៦-សម្រាប់ឆ្នាំ ២០២៤ ខាងមុខនេះ, សេដ្ឋកិច្ចកម្ពុជា ត្រូវបានព្យាករថានឹងសម្រេចបាននូវអត្រាកំណើនក្នុងរង្វង់ ៦,៦% ដោយសារការរំពឹងទុកនៃការត្រឡប់មករកភាពល្អប្រសើរឡើងវិញនៃតម្រូវការខាងក្រៅ និងទំនុកចិត្តវិនិយោគ ស្របពេលសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក នៅបន្តរក្សាបានតុល្យភាព។ ទន្ទឹមនេះ, ការអនុវត្ត "ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ ២០២១-២០២៣" ក្នុងពេលកន្លងមក ទាំងលើការស្តារវិស័យជាចន្ទល់កំណើនដែលមានស្រាប់ ក៏ដូចជាការលើកកម្ពស់វិស័យសក្តានុពលថ្មីៗមួយចំនួនទៀត រួមមាន៖ ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងបៃតង នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញ និងបង្កើនតម្លៃបន្ថែមដល់សេដ្ឋកិច្ច។ ទោះបីជាក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ នឹងត្រូវបានបញ្ចប់នៅឆ្នាំ ២០២៣ នេះ, រាជរដ្ឋាភិបាលនឹងបន្តផ្តោតជាសំខាន់លើការបន្តធ្វើការកែទម្រង់ឱ្យកាន់តែស៊ីជម្រៅ សំដៅបង្កើនភាពប្រកួតប្រជែង និងកសាងភាពធន់នៃសង្គម-សេដ្ឋកិច្ចកម្ពុជា ដោយឈរលើអភិក្រមដែលមានស្រាប់។

ដូចនេះ, ការប៉ាន់ស្មាន និងការព្យាករកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងអត្រា ៥,៦% សម្រាប់ឆ្នាំ ២០២៣ និង ៦,៦% សម្រាប់ឆ្នាំ ២០២៤ គឺត្រូវបានគិតគូរក្នុងកម្រិតបន្ទាត់មូលដ្ឋាន (Baseline projection) ស្របពេលដែលទស្សនវិស័យសេដ្ឋកិច្ចសកល និងតំបន់ កាន់តែមានភាពមិនប្រាកដប្រជាខ្ពស់។ ផ្អែកលើសម្មតិកម្មក្នុងកម្រិតបន្ទាត់មូលដ្ឋានខាងលើនេះ សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២៤ ត្រូវបានគាំទ្រដោយ៖ (១)-**វិស័យកសិកម្ម** ត្រូវបានព្យាករថានឹងសម្រេចបានកំណើនក្នុងរង្វង់ **១,១%** ដែលគាំទ្រដោយកំណើននៃអនុវិស័យដំណាំ និងអនុវិស័យចិញ្ចឹមសត្វ ស្របពេលដែលអនុវិស័យនេសាទរំពឹងថានឹងបន្តងើបឡើងវិញសន្សឹមៗ, (២)-**វិស័យឧស្សាហកម្ម** ត្រូវបានព្យាករថានឹងសម្រេចបានកំណើនក្នុងអត្រា ៨,៥% ដែលទ្រទ្រង់ដោយកំណើនល្អប្រសើរនៃអនុវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ ខណៈអនុវិស័យសំណង់បន្តសម្រេចបានកំណើនទាបជាងនិន្នាការមុនវិបត្តិកូវីដ-១៩ និង (៣)-**វិស័យសេវាកម្ម** ត្រូវបានព្យាករថានឹងបន្តនិន្នាការកើនឡើងក្នុងអត្រា ៦,៩% ដោយការបន្តកើនឡើងនូវសកម្មភាពក្នុងអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន និងសេវាកម្មគាំទ្រផ្សេងទៀត រួមមាន អនុវិស័យលក់ដុំ-រាយ និងអនុវិស័យដឹកជញ្ជូន និងគមនាគមន៍ ក្នុងខណៈដែលអនុវិស័យអចលនទ្រព្យ ត្រូវបានរំពឹងថានៅបន្តសម្រេចបានកំណើនទាបជាងនិន្នាការធម្មតា។

៧-ជារួម, សេដ្ឋកិច្ចកម្ពុជានៅឆ្នាំ ២០២៤, បាននិងកំពុងហ៊ុមព័ទ្ធដោយហានិភ័យ និងភាពមិនប្រាកដប្រជាដែលបណ្តាលមកពីកត្តាខាងក្រៅ រួមមាន៖ (១)-ការកើនឡើងនូវភាពតានតឹងភូមិសាស្ត្រនយោបាយតំបន់ និងសកល, (២)-ការថមថយសេដ្ឋកិច្ចសកល, (៣)-ការបន្តរឹតបន្តឹងយូរជាងការរំពឹងទុកនៃគោលនយោបាយរូបិយវត្ថុជាពិសេសសហរដ្ឋអាម៉េរិក និងការកើនឡើងថ្លៃរូបិយប័ណ្ណដុល្លារអាម៉េរិក ដែលអាចប៉ះពាល់ដល់លំហូរទុនវិនិយោគ និងពាណិជ្ជកម្ម, (៤)-ការបែកខ្ញែកនៃសេដ្ឋកិច្ច និងពាណិជ្ជកម្មសកលដែលនឹងប៉ះពាល់កិច្ចសហប្រតិបត្តិការអន្តរជាតិ និង (៥)-ការប្រែប្រួលអាកាសធាតុនិងគ្រោះធម្មជាតិ។ ទន្ទឹមនេះ, កម្ពុជាក៏នៅតែបន្តប្រឈមនឹងបញ្ហាជារចនាសម្ព័ន្ធខាងក្នុងប្រទេស ដែលធ្វើឱ្យការធ្វើពិពិធកម្មសេដ្ឋកិច្ចមានល្បឿនយឺត និងភាពប្រកួតប្រជែងមានកម្រិតក្នុងនោះរួមមាន៖ (១)-ថ្លៃដើមធ្វើធុរកិច្ចនៅមានកម្រិតខ្ពស់, (២)-ភាពមានកម្រិតនៃកិច្ចសម្រួលពាណិជ្ជកម្ម និងបរិយាកាសធុរកិច្ច, (៣)-ភាពមានកម្រិតនៃកម្លាំងពលកម្មជំនាញទាំងបរិមាណ និងគុណភាពដែលមិនទាន់អាចឆ្លើយតបទៅនឹងតម្រូវការទីផ្សារ, (៤)-ភាពមានកម្រិតនៃប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម និង (៥)-ភាពមានកម្រិតនៃចំណេះដឹង និងជំនាញក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថល។

៨-ក្នុងបរិការណ៍នេះ, រាជរដ្ឋាភិបាល បាននិងកំពុងបន្តដាក់ចេញដោយប្រទាក់ក្រឡានូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គោលនយោបាយរូបិយវត្ថុ និងគោលនយោបាយជារចនាសម្ព័ន្ធ ព្រមទាំងបន្តជំរុញឱ្យកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់នៃការអនុវត្តគោលនយោបាយទាំងនេះ សំដៅបន្តរក្សាលំនឹងនិងជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្ន។ ក្នុងទិសដៅបន្តកសាងភាពធន់សង្គម-សេដ្ឋកិច្ចឆ្លើយតបនឹងវិបត្តិដែលអាចកើតមាន រាជរដ្ឋាភិបាលនឹងបន្តជំរុញការស្តារ និងពង្រឹងចន្ទល់កំណើនសេដ្ឋកិច្ច ឱ្យរស់រវើក និងត្រឡប់ទៅកំណើនសក្តានុពល, ចាប់យកឱ្យបាននូវកាលានុវត្តភាពថ្មីៗ ដែលកំពុងលេចឡើង និងកសាងភាពធន់សង្គម-សេដ្ឋកិច្ច ឱ្យកាន់តែរឹងមាំ និងមានភាពឆ្លើយតបខ្ពស់។

៩-អត្រាអតិផរណា ត្រូវបានរំពឹងថានឹងត្រឡប់ទៅរកនិន្នាការធម្មតាវិញ ក្នុងអត្រា ២,៥% ដូចគ្នា សម្រាប់ឆ្នាំ ២០២៣ និងឆ្នាំ ២០២៤ ដោយសារការរំពឹងទុកនៃការវិលត្រឡប់ទៅរកប្រក្រតីភាពនៃថ្លៃប្រេងអន្តរជាតិ និងថ្លៃទំនិញផ្សេងៗទៀត។ ទន្ទឹមនេះ, អត្រាប្តូរប្រាក់ត្រូវបានរំពឹងថានឹងស្ថិតក្នុងរង្វង់អាចគ្រប់គ្រងបានក្នុងអត្រាជាមធ្យមប្រចាំឆ្នាំ ៤ ០៦៥ រៀល ក្នុងមួយដុល្លារអាម៉េរិក ក្នុងឆ្នាំ ២០២៣ និងឆ្នាំ ២០២៤ ដោយសារការអន្តរាគមន៍របស់ធនាគារជាតិនៃកម្ពុជា ក្នុងការរក្សាស្ថិរភាពថ្លៃ និងទំនុកចិត្តពីសាធារណជនលើការប្រើប្រាស់ប្រាក់រៀល។

១០-ឱនភាពគណនីចរន្ត (រួមបញ្ចូលបង្វែរ) ត្រូវបានព្យាករថានឹងបន្តរួមតូចមកវិញ ក្នុងទំហំ ១៣,៨% នៃ ផ.ស.ស. សម្រាប់ឆ្នាំ ២០២៣ និង ១១,១% នៃ ផ.ស.ស. សម្រាប់ឆ្នាំ ២០២៤ ដោយសារការរំពឹងទុកនៃការបន្តវិលត្រឡប់ទៅរកប្រក្រតីភាពវិញនៃសមតុល្យពាណិជ្ជកម្ម ស្របពេលដែលចំណូលពីភ្ញៀវទេសចរអន្តរជាតិ និងប្រាក់បង្វែរឯកជន ក៏បន្តនិន្នាការកើនឡើង។ ជាមួយគ្នានេះ, **វិហូរវិនិយោគផ្ទាល់ពីបរទេស** ត្រូវបានរំពឹងថានឹងបន្តងើបឡើងក្នុងរង្វង់ ១១,៨% នៃ ផ.ស.ស. សម្រាប់ឆ្នាំ ២០២៣ និងក្នុងរង្វង់ ១១,៧% នៃ ផ.ស.ស. សម្រាប់ឆ្នាំ ២០២៤ ដោយសារការបន្តងើបឡើងនៃទំនុកចិត្តវិនិយោគ ក្នុងបរិការណ៍នៃការផ្លាស់ប្តូរកាន់តែលឿននៃខ្សែច្រវាក់ផលិតកម្ម និងផ្គត់ផ្គង់សកល ជាមួយនឹងបរិយាកាសវិនិយោគកាន់តែអំណោយផលរបស់កម្ពុជា ដោយសារការដាក់ចេញ និងអនុវត្តនូវច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងការបន្តធ្វើកំណែទម្រង់កាន់តែស៊ីជម្រៅ និងមុតស្រួច ពិសេសការកាត់បន្ថយថ្លៃដើមធ្វើធុរកិច្ច។ ជាលទ្ធផល, **ទុនបម្រុងអន្តរជាតិសរុប** ត្រូវបានប៉ាន់ស្មានថានឹងបន្តកើនឡើងដល់ប្រមាណ ១៨ ៦៩២ លានដុល្លារអាម៉េរិក ដែលធានាការនាំចូលបានប្រមាណ ៦,៦ ខែ សម្រាប់ឆ្នាំ ២០២៣ និងដល់ប្រមាណ ១៩ ៩១៣ លានដុល្លារអាម៉េរិក ដែលធានាការនាំចូលបានប្រមាណ ៦,៣ ខែ សម្រាប់ឆ្នាំ ២០២៤។

## ២.២-ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

១១-ផ្អែកលើមូលដ្ឋានក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងការវិវត្តជាក់ស្តែងនៃស្ថានភាពហិរញ្ញវត្ថុសាធារណៈ, រាជរដ្ឋាភិបាលដាក់ចេញនូវ "គោលនយោបាយពង្រឹងប្រសិទ្ធភាពចំណាយ" (Fiscal Consolidation) នៅក្នុងឆ្នាំ ២០២៤ សំដៅជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ក្នុងបរិការណ៍នៃការចាកចេញពីវិបត្តិកូវីដ-១៩ និងលើកកម្ពស់កិច្ចអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។ ក្នុងន័យនេះ, ដោយឆ្នាំ ២០២៤ គឺជាឆ្នាំដំបូងនៃរាជរដ្ឋាភិបាល នីតិកាលទី ៧, រាជរដ្ឋាភិបាលគិតគូរយ៉ាងហ្មត់ចត់លើអាទិភាពចំណាយប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ ដើម្បីបន្តពង្រឹងសមត្ថភាពស្ថាប័ន និងលើកកម្ពស់សមត្ថភាពមន្ត្រី ពិសេស គាំទ្រដល់ការអនុវត្តកម្មវិធីគោលនយោបាយអាទិភាពនានា ស្របពេលដែលទស្សនវិស័យនៃការប្រមូលចំណូលប្រឈមនឹងការកំណើនយឺតជាងមុនវិបត្តិជំងឺកូវីដ-១៩។ ដូចនេះ ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៤ កំណត់យកអាទិភាពសំខាន់ៗ ដូចខាងក្រោម៖

- បន្តពង្រឹងសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ,
- បន្តធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចក្នុងរយៈពេលមធ្យមប្រកបដោយបរិយាប័ន្ន,
- បន្តស្តារ និងជំរុញកំណើនសេដ្ឋកិច្ច ឱ្យស្ទុះងើបឡើងវិញ ដោយ*បង្កើនការវិនិយោគដើម្បីបង្កើនតម្លៃបន្ថែមលើមូលដ្ឋានកំណើនសេដ្ឋកិច្ចដែលមានស្រាប់ ព្រមទាំងជំរុញឱ្យមានការវិនិយោគទៅលើប្រភពថ្មីនៃកំណើនដែលមានសក្តានុពលសេដ្ឋកិច្ច និងមានផលិតភាពខ្ពស់* ដើម្បីបន្តបង្កើតការងារជូនប្រជាជន, ជាពិសេសស្រទាប់យុវជន, និងដើម្បីផ្តល់លទ្ធភាពឱ្យប្រជាជនទទួលបានប្រាក់ចំណូលខ្ពស់ឡើងវិញផង និងជំរុញបង្កើនចំណូលថវិកាជាតិផង,
- *ពង្រឹងសមត្ថភាពរបស់មន្ត្រីរាជការ និងលើកទឹកចិត្តចំពោះមន្ត្រីដែលមានគុណវុឌ្ឍិ* ទន្ទឹមគ្នានឹងការបន្តដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ក្នុងគោលដៅលើកកម្ពស់ជីវភាពរស់នៅ, បង្កើនផលិតភាពការងារ និងពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដោយឈរលើគោលការណ៍សមធម៌, គុណាធិបតេយ្យ និងចីរភាពថវិកា, ជាពិសេស
- *ពង្រឹងប្រព័ន្ធគាំពារសង្គម ដែលមានចរិតចំគោលដៅ* ព្រមទាំងជំរុញការអភិវឌ្ឍប្រព័ន្ធសុខាភិបាល ដើម្បីលើកកម្ពស់សុខុមាលភាពសង្គម និងកសាងភាពធន់នៃសង្គមកម្ពុជា ដែលអាចឆ្លើយតបនឹងគ្រោះអាសន្នដែលអាចកើតមានជាយថាហេតុ,
- *ជំរុញការអភិវឌ្ឍធនធានមនុស្ស* ដោយការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសគ្រប់កម្រិត ដើម្បីផ្គត់ផ្គង់ពលករជំនាញប្រកបដោយផលិតភាពខ្ពស់ ឱ្យបាន-គ្រប់គ្រាន់ និងឆ្លើយតបនឹងតម្រូវការទីផ្សារ,
- *ពង្រឹងភាពប្រកួតប្រជែង និងពិពិធកម្មសេដ្ឋកិច្ចកម្ពុជា* ដោយបន្តគាំទ្រការអភិវឌ្ឍនៃសហគ្រាសធុនតូច និងមធ្យម តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីវិនិយោគថ្មីក្នុងការទាក់ទាញវិនិយោគ និងការ-ដាក់ចេញវិធានការលើកទឹកចិត្តជាក់លាក់ ព្រមទាំងការកែលម្អបរិយាកាសធុរកិច្ច
- *បង្កើនគុណភាព និងប្រសិទ្ធភាពនៃការវិនិយោគសាធារណៈជាទូទៅ, បន្តការវិនិយោគទៅលើហេដ្ឋា-រចនាសម្ព័ន្ធចាំបាច់ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចនិងលើកកម្ពស់ជីវភាពប្រជាជន ក៏ដូចជាការផ្តល់សេវាសាធារណៈផ្សេងៗ, និង បង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការអភិវឌ្ឍបៃតង* សំដៅជំរុញការតភ្ជាប់ក្នុងសេដ្ឋកិច្ច, គាំទ្រការធ្វើបរិវត្តកម្មឌីជីថល និងអភិវឌ្ឍប្រកបដោយចីរភាព, និង
- បន្តជំរុញការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកម្មវិធីកែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ។

### ២.២.១-ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៤-២០២៦

១២-ផ្អែកតាមក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដូចបានកំណត់ខាងលើ ពិតានចំណាយគោលតាមវិស័យឆ្នាំ ២០២៤-២០២៦ ត្រូវបានកំណត់ដូចតទៅ៖

-*វិស័យរដ្ឋបាលទូទៅ* ត្រូវបានគ្រោងប្រមាណ ១,៩៩%, ១,៩៩%, និង ១,៩៣% នៃ ផ.ស.ស. សម្រាប់ឆ្នាំ ២០២៤, ២០២៥ និង ២០២៦ រៀងគ្នា,

-*វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ* ត្រូវបានគ្រោងប្រមាណ ៣,៨៣%, ៣,៦៧%, និង ៣,៥៤% នៃ ផ.ស.ស. សម្រាប់ឆ្នាំ ២០២៤, ២០២៥ និង ២០២៦ រៀងគ្នា,

-*វិស័យសង្គមកិច្ច* ត្រូវបានគ្រោងប្រមាណ ៦,៤៨%, ៦,៤៧%, និង ៦,៤៧% នៃ ផ.ស.ស. សម្រាប់ឆ្នាំ ២០២៤, ២០២៥ និង ២០២៦ រៀងគ្នា,

-*វិស័យសេដ្ឋកិច្ច* ត្រូវបានគ្រោងប្រមាណ ៦,៩៩%, ៧,៣៨%, និង ៧,៩៥% នៃ ផ.ស.ស. សម្រាប់ឆ្នាំ ២០២៤, ២០២៥ និង ២០២៦ រៀងគ្នា។

១៣-ក្របខ័ណ្ឌពិតានចំណាយគោលកម្រិតវិស័យនេះ ត្រូវបានគិតបញ្ចូលទាំងចំណាយចរន្ត និងចំណាយមូលធន ទាំងលទ្ធភាពហិរញ្ញប្បទានដោយថវិកាជាតិ និងលទ្ធភាពហិរញ្ញប្បទានក្រៅប្រទេស ទាំងទ្វេភាគី និងពហុភាគី។ ដូចនេះ, ផ្អែកលើមូលដ្ឋានខាងលើនេះ, ក្របខ័ណ្ឌថវិការយៈពេលមធ្យម (ក.ថ.ម) បានកំណត់**ពិតានចំណាយគោលផ្នែកចំណាយចរន្ត** ជូនដល់គ្រប់ក្រសួង-ស្ថាប័ន។ ដោយឡែក **ពិតានចំណាយគោលផ្នែកចំណាយមូលធនសម្រាប់គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាថ្នាក់ជាតិ និងដោយហិរញ្ញប្បទានក្រៅប្រទេស** ត្រូវបានកំណត់សម្រាប់ក្រសួង-ស្ថាប័នចំនួន ៩ រួមមាន៖ ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងមហាផ្ទៃ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងសុខាភិបាល និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ ការកំណត់ពិតានចំណាយគោលដល់កម្រិតក្រសួង-ស្ថាប័ន ធ្វើឡើងដើម្បីពង្រឹងគុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា, ការបន្តពង្រឹងវិន័យថវិកា, ការបង្កើនប្រសិទ្ធភាពចំណាយ និងការកែលម្អការវិភាជធនធានសាធារណៈជារួម។ ដូចនេះ, **ពិតានចំណាយគោលឆ្នាំ ២០២៤-២០២៦** ផ្តល់នូវការធានាធនធានហិរញ្ញវត្ថុ និងថវិកាជូនដល់គ្រប់ក្រសួង-ស្ថាប័ន ***ដូចដែលបានរៀបចំ និងមានភ្ជាប់ជូនក្នុងតារាង ១ និងឧបសម្ព័ន្ធ ១*** សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៤-២០២៦ ក៏ដូចជាសម្រាប់ការរៀបចំគម្រោងថវិកាឆ្នាំ ២០២៤ ដែលក្រសួង-ស្ថាប័ននីមួយៗ ត្រូវស្នើឡើង។

## ២.២.២-ក្របខ័ណ្ឌថវិកាឆ្នាំ ២០២៤

១៤-ក្នុងបរិបទ និងទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ច និងក្នុងទិសដៅសម្រេចឱ្យបាននូវគោលបំណងនៃក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈខាងលើនេះ រាជរដ្ឋាភិបាលបានកំណត់ក្របខ័ណ្ឌថវិកាឆ្នាំ ២០២៤ រួមជាមួយនឹងវិធានការគោលនយោបាយជាក់លាក់ ទាំងផ្នែកចំណូល និងផ្នែកចំណាយសម្រាប់ឆ្នាំ ២០២៤ ដូចខាងក្រោម៖

### ២.២.២.១-ក្របខ័ណ្ឌចំណូលថវិកាឆ្នាំ ២០២៤

១៥-ចំណូលសរុបថវិការដ្ឋសម្រាប់ឆ្នាំ ២០២៤ គ្រោងសម្រេចឱ្យបាន ២៣,០៧% នៃ ផ.ស.ស. ក្នុងនោះ៖

- ចំណូលចរន្តថវិការដ្ឋត្រូវសម្រេចឱ្យបានប្រមាណ ២២,៣៣% នៃ ផ.ស.ស. គឺកើនឡើង ០,៨ ពិន្ទុភាគរយនៃ ផ.ស.ស. ឬកើនឡើង ១៣,៣% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៣។ **ចំណូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា** ត្រូវគ្រោងសម្រេចឱ្យបាន ៧,៧៨% នៃ ផ.ស.ស. គឺថយចុះ ០,៧៣ ពិន្ទុភាគរយនៃ ផ.ស.ស. ឬថយចុះ ០,២% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៣, ចំណូល

**ពីអគ្គនាយកដ្ឋានពន្ធដារ** ត្រូវគ្រោងសម្រេចឱ្យបាន ១១,៧៩% នៃ ផ.ស.ស. គឺកើនឡើង ០,៧៤ ពិន្ទុភាគរយនៃ ផ.ស.ស. ឬកើនឡើង ១៦,៦% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៣, និង**ចំណូលមិនមែនសារពើពន្ធ** ត្រូវគ្រោងសម្រេចឱ្យបាន ២,៧៦% នៃ ផ.ស.ស. គឺកើនឡើង ០,៧៩ ពិន្ទុភាគរយនៃ ផ.ស.ស. ឬកើនឡើង ៥៣,៣% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៣។

- **ចំណូលផ្សេងៗក្នុងប្រទេស** ត្រូវសម្រេចឱ្យបាន ០,២៥% នៃ ផ.ស.ស.។
- ចំណែកឯ **ចំណូលផ្សេងៗដោយហិរញ្ញប្បទានក្រៅប្រទេសសម្រាប់អនុវត្តគម្រោងវិនិយោគសាធារណៈ** គ្រោងសម្រេចឱ្យបាន ០,៤៤% នៃ ផ.ស.ស. ហើយ**មូលនិធិទ្រទ្រង់ថវិកា**គ្រោងសម្រេចឱ្យបាន ០,០៥% នៃ ផ.ស.ស.។

ដើម្បីសម្រេចគោលដៅចំណូលសរុបខាងលើនេះ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់លើការជំរុញនិងពង្រឹងការអនុវត្តគោលនយោបាយ និងច្បាប់ដែលមានស្រាប់ តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់ និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាល និងវិធានការគោលនយោបាយ ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល ក្នុងផ្នែកគយនិងរដ្ឋាករ ផ្នែកពន្ធដារ និងផ្នែកចំណូលមិនមែនសារពើពន្ធ។

### ២.២.២.១.១-ផ្នែកចំណូលពន្ធដារ

១៦-វិធានការគន្លឹះសម្រាប់អនុវត្តក្នុងឆ្នាំ ២០២៤ ដើម្បីគាំទ្រសកម្មភាពនៃអាជីវកម្មក្នុងស្រុក និងរក្សាចីរភាពកំណើនចំណូល ដែលនឹងត្រូវអនុវត្តដោយអគ្គនាយកដ្ឋានពន្ធដារ រួមមាន៖

- បន្តពង្រឹងការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស ព្រមទាំងបន្តតាមដានការបំពេញកាតព្វកិច្ចសារពើពន្ធសម្រាប់រាល់សហគ្រាសដែលបានចុះបញ្ជីពន្ធដារ ក្នុងគោលដៅពង្រីកនូវមូលដ្ឋានពន្ធ តាមរយៈការពង្រឹងយន្តការចុះបញ្ជីសហគ្រាសថ្មី និងពង្រឹងការគ្រប់គ្រងនូវការប្រមូលចំណូលពន្ធ ក៏ដូចជាកាត់បន្ថយហានិភ័យពាក់ព័ន្ធនានា,
- ដំឡើងកម្រិតជាប់ពន្ធក្នុងតារាងភាគនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ និងតារាងភាគនៃបៀវត្សជាប់ពន្ធប្រចាំខែ, ដាក់ឱ្យអនុវត្តការប្រមូលចំណូលពន្ធលើចំណេញមូលធន និងពិនិត្យនិងកែសម្រួលឡើងវិញអត្រាអាករបំភ្លឺសាធារណៈ,
- ពង្រឹងការប្រមូលចំណូលតាមវិស័យដែលនៅមានសក្តានុពល ដូចជា វិស័យសំណង់, វិស័យទូរគមនាគមន៍, វិស័យរ៉ែ, វិស័យផលិតស្រាបៀរ, កេសជ្ជៈ និងថ្នាំជក់ ជាដើម,
- ពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលពាក់ព័ន្ធនឹងអចលនទ្រព្យ ដោយធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យ, ពង្រឹងអនុលោមភាពនៃការបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់, និង ពង្រឹងការបង់ពន្ធប្រថាប់ត្រា ចំពោះការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុននៅក្នុងកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋាននានា,
- ពង្រឹងការប្រមូលចំណូលពន្ធ ជាពិសេសអាករលើតម្លៃបន្ថែម លើការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថល ដែលធ្វើប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក,
- បន្តចូលរួមជាមួយស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធ នៃច្រកចេញ-ចូលនៃប្រព័ន្ធអ៊ីនធឺណិតជាតិ ( National Internet Gateway ) និងប្រព័ន្ធទូទាត់ ( Payment Gateway ) ,

- បន្តកែលម្អ និងធ្វើឱ្យកាន់តែប្រសើរឡើងនូវមុខងារស្នូលទាំង ៣ រួមមាន E-registration, E-filling, និង E-payment ដោយប្រើប្រាស់ថ្នាលបច្ចេកវិទ្យារួម ដែលមានភាពប្រឡាក់ក្រឡា, ស្វ័យប្រវត្តិកម្មពេញលេញ និង ផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធ,
- បន្តដាក់អនុវត្តផែនការជាតិស្តីពីសវនកម្ម (National audit plan) ដើម្បីកំណត់អត្តសញ្ញាណជាយុទ្ធសាស្ត្រ ក្នុងការវិភាគហានិភ័យ និងពង្រឹងការធ្វើសវនកម្មដោយផ្អែកលើកម្រិតហានិភ័យ (Risk-Based Audit), និង
- ធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសដែលជំពាក់បំណុលពន្ធ និងពង្រឹងយន្តការតាមដាន និងតឹងទារបំណុលពន្ធ។

**២.២.២.១.២-ផ្នែកចំណូលគយ និងរដ្ឋាករ**

១៧-វិធានការគន្លឹះ ដែលគ្រោងនឹងដាក់ឱ្យអនុវត្តក្នុងឆ្នាំ ២០២៤ ដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នឹងផ្តោតលើគោលដៅជាអាទិភាព ដូចខាងក្រោម៖

- បន្តអនុវត្តការលើកទឹកចិត្តពន្ធគយ និងពង្រឹងការអនុវត្តបទប្បញ្ញត្តិថ្មីៗ ស្របទៅនឹងការលើកទឹកចិត្ត សម្រាប់វិស័យអាទិភាព ជាពិសេសសហគ្រាសធុនតូច និងមធ្យម,
- បន្តពិនិត្យ និងកែលម្អគោលនយោបាយពន្ធ និងអាករ សម្រាប់វិស័យអាទិភាព និងមុខទំនិញនានាឱ្យស្របតាមតម្រូវការចាំបាច់ និងការវិវឌ្ឍនៃមុខទំនិញទាំងនោះ,
- បន្តធ្វើសាមញ្ញកម្ម និងទំនើបកម្មនីតិវិធីគយ និងកិច្ចប្រតិបត្តិការគយផ្សេងទៀត ស្របតាមស្តង់ដារអន្តរជាតិ សំដៅបង្កើនគុណភាពនៃការផ្តល់សេវា និងភាពពេញចិត្តរបស់ធុរជន,
- បន្តការបញ្ជ្រាបចំណេះដឹងលើនីតិវិធីគយដល់ធុរជន ដោយផ្សព្វផ្សាយមគ្គុទ្ទេសក៏គិតពន្ធ ចំណាត់ថ្នាក់ទំនិញ និងនីតិវិធីអនុគ្រោះពន្ធក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី,
- បន្តការលើកទឹកចិត្តធុរជន ដែលភ្ជាប់ជាមួយកម្មវិធីធុរជនល្អបំផុត (Best Trader) និងកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត (Authorized Economic Operator Program),
- ជំរុញការអនុវត្តនីតិវិធី ដោយពង្រឹងការងារបង្ការ ការងារបង្ក្រាបបទល្មើសគយ និងអនុវត្តតុលាការគយចំពោះបទល្មើសគយ ដែលមិនអាចសម្រុះសម្រួលដោយរដ្ឋបាលគយ,
- រៀបចំដាក់ឱ្យអនុវត្តប្រព័ន្ធកត់ត្រាកម្មសិទ្ធិបញ្ញា និងធ្វើទំនើបកម្មប្រព័ន្ធ ដើម្បីឱ្យស្របតាមស្តង់ដារអន្តរជាតិ ក្នុងការប្រកួតប្រជែងស្មើភាព ការបំពេញបែបបទបញ្ចេញទំនិញ និងប្រព័ន្ធត្រួតពិនិត្យ,
- បន្តកែលម្អប្រសិទ្ធភាពការងារគ្រប់គ្រងហានិភ័យ តាមរយៈការកែលម្អវិធីសាស្ត្រ និង លក្ខណៈវិនិច្ឆ័យជ្រើសរើសសូចនាករហានិភ័យ,
- ពង្រីកវិសាលភាពនៃការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ ឈានទៅដំណាក់កាលទី ៣ និងតភ្ជាប់បញ្ជរតែមួយជាតិកម្ពុជាទៅនឹងបញ្ជរតែមួយអាស៊ាន, និង
- ពង្រឹងវិធានការអនុវត្ត និងសិក្សាលើការប្រមូលចំណូលលើទំនិញប្រណិត ទំនិញប៉ះពាល់សុខភាព និងទំនិញប៉ះពាល់ដល់បរិស្ថាន។

### ២.២.២.១.៣-ផ្នែកចំណូលមិនមែនសារពើពន្ធ

១៨-ដើម្បីបន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងទ្រព្យសម្បត្តិរដ្ឋ និងការប្រមូលចំណូលពីប្រភពដែលមានសក្តានុពល, វិធានការគន្លឹះចាំបាច់ត្រូវបន្តអនុវត្ត រួមមាន៖

- បន្តជំរុញការអនុវត្តច្បាប់ បទប្បញ្ញត្តិ គោលការណ៍ណែនាំ និងបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ,
- ជំរុញការរៀបចំឯកសារគោល (Blueprint) ស្តីពីការកែទម្រង់ប្រព័ន្ធចំណូលមិនមែនសារពើពន្ធ,
- ជំរុញការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងបញ្ជីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ (SARMIS) នៅរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ,
- ត្រួតពិនិត្យលើការប្រមូលចំណូលសួយសារធនធានរ៉ែ ផ្អែកលើការកែសម្រួលអត្រាសួយសារលើតម្លៃផលិតផលរ៉ែ និងនីតិវិធីនៃការបង់ថ្លៃសួយសារ,
- បន្តតាមដាន ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ការបង់ចំណូលសួយសារធនធានរ៉ែ និងបរិមាណក្រុមហ៊ុនដែលកំពុងប្រកបអាជីវកម្ម តាមរយៈក្រុមការងារអន្តរក្រសួង,
- ជំរុញការអនុវត្តការប្រមូលចំណូលពីឈ្នួលសម្បទានដីសេដ្ឋកិច្ច ដោយផ្អែកលើកិច្ចសន្យា និងគោលការណ៍ គណនាថ្លៃឈ្នួលសម្បទានដីសេដ្ឋកិច្ចឡើងវិញ,
- ពន្លឿនការកែសម្រួលប្រកាសអន្តរក្រសួង អំពីការកំណត់ថ្លៃឈ្នួលដីឡើងវិញ នៅតំបន់អាជ្ញាបណ្ណធនធានរ៉ែ,
- បន្តជំរុញការអនុវត្តការបង់ចំណូលពីសម្បទានដីសេដ្ឋកិច្ច និងធនធានរ៉ែ តាមរយៈប្រព័ន្ធបង់ប្រាក់អេឡិចត្រូនិក និងបង់ប្រាក់រំដោះឱ្យបានទៀងទាត់ ដោយមានការធ្វើអធិការកិច្ចពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ,
- បន្តតាមដាន និងគ្រប់គ្រងចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋ តាមរយៈកិច្ចសន្យាជួល និងការគណនាតម្លៃជួលថ្មីផ្អែកតាមតម្លៃគិតពន្ធប្រថាប់ត្រាផ្ទេរអចលនទ្រព្យ,
- ដកហូតមកវិញនូវចំនួនហ្វ្រេកង់ដែលមិនប្រើប្រាស់ និងរៀបចំដាក់ដេញថ្លៃឡើងវិញ ដើម្បីកៀរគរចំណូលបន្ថែម,
- បន្តពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលពី វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីរក្សាឱ្យបាននូវស្ថិរភាពចំណូល,
- បន្តរៀបចំយន្តការទប់ស្កាត់កុំឱ្យមានបំណុលថ្មី និងពង្រឹងការតឹងទារបំណុល តាមរយៈគណៈកម្មការអន្តរក្រសួង,
- បន្តពិនិត្យ និងពិភាក្សាលើការកៀរគរប្រភពចំណូលមិនមែនសារពើពន្ធថ្មី។

### ២.២.២.២-ក្របខ័ណ្ឌចំណាយថវិកាឆ្នាំ ២០២៤

១៩-ក្នុងការត្រៀមខ្លួនឱ្យបានរួចរាល់ក្នុងការឆ្លើយតបទៅនឹងហានិភ័យដែលអាចកើតឡើងជាយថាហេតុ និងអនុវត្តអន្តរាគមន៍ចាំបាច់នានា, គម្រោងចំណាយថវិកាឆ្នាំ ២០២៤ ត្រូវបានកំណត់ និងវិភាជតាមក្របខ័ណ្ឌរួមដូចខាងក្រោម៖

❖ **ចំណាយសរុបថវិកាជាតិ** នៅឆ្នាំ ២០២៤ នឹងកំណត់ក្នុងរង្វង់ ២៦,២៩% នៃ ផ.ស.ស. គឺថយចុះ ៣,៦៨ ពិន្ទុភាគរយនៃ ផ.ស.ស. ឬថយចុះ ៤,២% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣ (ហៅកាត់ថា ច្បាប់ថវិកាឆ្នាំ ២០២៣) ក្នុងនោះ ចំណាយសរុបថវិកាថ្នាក់ជាតិ ២៤,៤២% នៃ ផ.ស.ស. និង ចំណាយសរុបថវិកាថ្នាក់ក្រោមជាតិ ២,៩៦% នៃ ផ.ស.ស. ដោយរួមបញ្ចូលទាំងការឧបត្ថម្ភធនដល់ថ្នាក់ក្រោមជាតិ ចំនួន ១,០៩% នៃ ផ.ស.ស.។

- **ចំណាយចរន្តថវិការដ្ឋ** ត្រូវកំណត់ក្នុងកម្រិត ១៨,៤៣% នៃ ផ.ស.ស. គឺកើនឡើង ០,៩ ពិន្ទុភាគរយ នៃ ផ.ស.ស. ឬកើនឡើង ១៤,៩% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៣ ដែលក្នុងនោះ៖
  - **ចំណាយបន្ទុកបុគ្គលិក**មានសមាមាត្រស្មើនឹង ៤១,៨% នៃចំណាយចរន្តថវិការដ្ឋ ត្រូវជា ៧,៧% នៃ ផ.ស.ស. ដោយផ្តោតអាទិភាពទៅលើការដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ ក្នុងគោលដៅលើកកម្ពស់ជីវភាពរស់នៅ, បង្កើនផលិតភាពការងារ និងពង្រឹងប្រសិទ្ធភាព នៃការផ្តល់សេវាសាធារណៈ ដោយឈរលើគោលការណ៍សមធម៌, គុណាធិបតេយ្យ និង ចីរភាពថវិកា,
  - **ចំណាយក្រៅបន្ទុកបុគ្គលិក**មានសមាមាត្រស្មើនឹង ៥៨,២% នៃចំណាយចរន្តថវិការដ្ឋ ត្រូវជា ១០,៧៣% នៃ ផ.ស.ស. ដោយផ្តោតអាទិភាពទៅលើ៖ (១)-ការពង្រឹងប្រព័ន្ធគាំពារសង្គម ដែលមានចរិតចំគោលដៅ ព្រមទាំងជំរុញការអភិវឌ្ឍប្រព័ន្ធសុខាភិបាល ដើម្បីលើកកម្ពស់ សុខុមាលភាពសង្គម និងកសាងភាពធន់នៃសង្គមកម្ពុជា; (២)-រៀបចំមូលដ្ឋានសង្គមកម្ពុជា ឱ្យកាន់តែមានភាពធន់រឹងមាំ តាមរយៈការពន្លឿនការកែទម្រង់ក្នុងវិស័យអប់រំ, ការលើកកម្ពស់ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេសជំនាញគ្រប់កម្រិត; និង (៣)-សម្រេចឱ្យបាន នូវរាល់គោលដៅអាទិភាពនៃរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល។
- **ចំណាយមូលធន** ត្រូវបានគ្រោងប្រមាណ ៧,៨៥% នៃ ផ.ស.ស. គឺថយចុះ ៤,៥៩ ពិន្ទុភាគរយនៃ ផ.ស.ស. ឬថយចុះ ៣១,០% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៣ ក្នុងគោលដៅស្តារ និងអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា រួមទាំងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាព ខ្ពស់, ហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងបៃតង ក៏ដូចជាពង្រឹងមូលដ្ឋានអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ឱ្យកាន់តែរឹងមាំ បន្ទាប់ពីវិបត្តិនៃជំងឺកូវីដ-១៩ ជាពិសេសជំរុញវិស័យដែលជាចន្ទល់កំណើន និង ផលិតភាពសេដ្ឋកិច្ច។
- **ចំណាយសរុបថវិកាថ្នាក់ជាតិ** ដែលរួមបញ្ចូលទាំងហិរញ្ញប្បទានក្រៅប្រទេស ត្រូវបានគ្រោងវិភាជ ទៅតាមវិស័យ ដូចខាងក្រោម៖
  - **ចំណាយវិស័យរដ្ឋបាលទូទៅ** ត្រូវបានគ្រោងប្រមាណ ១,៩៩% នៃ ផ.ស.ស. ដើម្បីបន្តគាំទ្រ ការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ, ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងការទូត និងការអនុវត្តច្បាប់ស្តីពី វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។
  - **ចំណាយវិស័យការពារជាតិ, សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** ត្រូវបានគ្រោងប្រមាណ ៣,៨៣% នៃ ផ.ស.ស. សំដៅគាំទ្រការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌, ការលើកកម្ពស់

សុខុមាលភាព និងការពង្រឹងសមត្ថភាពរបស់កងកម្លាំងប្រដាប់អាវុធ ក្នុងបុព្វហេតុធានាកិច្ចការពារជាតិ និងរក្សាសន្តិភាព និងស្ថិរភាពនយោបាយ។

- **ចំណាយវិស័យសង្គមកិច្ច** ត្រូវបានគ្រោងប្រមាណ ៦,៤៨% នៃ ផ.ស.ស. សំដៅបន្តលើកកម្ពស់គុណភាព និងពង្រីកវិសាលភាពនៃការទទួលបានសេវាសុខាភិបាល, ពង្រឹងប្រព័ន្ធសុខភាពសាធារណៈ ដែលអាចឆ្លើយតបនឹងគ្រោះអាសន្ននាពេលអនាគត, អនុវត្តយុទ្ធសាស្ត្រស្តីពីការរស់នៅតាមបែបគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩, បន្តវិនិយោគលើគោលនយោបាយលើកកម្ពស់ការអប់រំ, ព្រមទាំងគាំទ្រដល់ការអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ ២០១៦-២០២៥, គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ ២០១៧-២០២៥, និងគោលនយោបាយអាទិភាពផ្សេងទៀត លើផ្នែកសង្គមកិច្ច សាសនា វប្បធម៌ និងបរិស្ថាន ជាពិសេស ការប្រែប្រួលអាកាសធាតុ។
- **ចំណាយវិស័យសេដ្ឋកិច្ច** ត្រូវបានគ្រោងប្រមាណ ៦,៩៩% នៃ ផ.ស.ស. ដោយផ្តោតសំខាន់លើការគាំទ្រដល់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម, ការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជាឆ្នាំ ២០២២-២០២៧, យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, គោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ឆ្នាំ ២០២០-២០៣០, ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាឆ្នាំ ២០២១-២០៣៥, គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជាឆ្នាំ ២០២២-២០៣៥, គោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០២១-២០៣០ និងការអនុវត្តផែនទីចង្អុលផ្លូវស្តីពីផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុងនិងក្រោយវិបត្តិជំងឺកូវីដ-១៩ ឆ្នាំ ២០២០-២០២៥, ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាបឆ្នាំ ២០២១-២០៣៥ និង ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរីឆ្នាំ ២០២១-២០៣៥ ជាដើម។
- **ចំណាយផ្សេងៗ** ត្រូវបានគ្រោងប្រមាណ ៥,១៣% នៃ ផ.ស.ស. ដើម្បីធានាបាននូវភាពទន់ភ្លន់ និងលទ្ធភាពនៃការឆ្លើយតបទៅនឹងគោលនយោបាយអាទិភាពថ្មីៗនៃរាជរដ្ឋាភិបាលអាណត្តិថ្មី ក៏ដូចជាអន្តរាគមន៍ភ្លាមៗក្នុងការដោះស្រាយនូវបញ្ហាសង្គម-សេដ្ឋកិច្ច និងត្រៀមបម្រុងសម្រាប់ការអនុវត្តគោលនយោបាយអាទិភាពនានា, ការឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងកិច្ចការបន្ទាន់ចំពោះមុខរបស់រាជរដ្ឋាភិបាល ដូចជាការត្រៀមបម្រុងសម្រាប់គ្រោះមហន្តរាយធម្មជាតិ និងស្បៀងបម្រុង ។ល។ ដោយឡែក, សម្រាប់ការអនុវត្តជាក់ស្តែង ចំណាយថវិកាដែលបានគ្រោងក្នុងផ្នែកចំណាយផ្សេងៗនេះ នឹងត្រូវវិភាជទៅតាមវិស័យទាំង ៤ ខាងលើ ស្របតាមគោលដៅនៃមុខចំណាយនីមួយៗ។

- **ចំណាយចរន្តថវិកាថ្នាក់ជាតិ** ត្រូវកំណត់ត្រឹម ១៦,៩៤% នៃ ផ.ស.ស. កើនឡើង ១៦,២% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៣ ដែលក្នុងនោះ **ចំណាយបុគ្គលិក**មានសមាមាត្រស្មើនឹង ៤១,៦% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា ៧,០៥% នៃ ផ.ស.ស. និងចំណាយក្រៅ

បន្ទុកបុគ្គលិកមានសមាមាត្រស្មើនឹង ៥៨,៤% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា ៩,៨៨% នៃ ផ.ស.ស.។

- **ចំណាយចរន្តថវិកាថ្នាក់ក្រោមជាតិ** ត្រូវកំណត់ត្រឹម ២,៥៩% នៃ ផ.ស.ស. កើនឡើង ៤,២% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៣ ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក ០,៦៥% នៃ ផ.ស.ស. និងចំណាយក្រៅបន្ទុកបុគ្គលិក ១,៩៤% នៃ ផ.ស.ស. ដែលត្រូវប្រើប្រាស់ថវិកាផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ សរុបមានប្រមាណ ១,៨៧% នៃ ផ.ស.ស. និងថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិស្មើនឹង ១,០៩% នៃ ផ.ស.ស.។

២០-ក្នុងក្របខ័ណ្ឌនៃគោលដៅរក្សាស្ថិរភាពសង្គម និងទ្រទ្រង់បាននូវការងើបឡើងវិញនៃកំណើនសេដ្ឋកិច្ច, រាជរដ្ឋាភិបាល ចាំបាច់ត្រូវពង្រឹងប្រសិទ្ធភាពថវិកា ទាំងកម្រិតវិភាជន៍ ព្រមទាំងប្រតិបត្តិការ និងការឆ្លើយតបនឹងទិសដៅគោលនយោបាយ និងកម្មវិធីកែទម្រង់នានានៅក្នុងឆ្នាំ ២០២៤ តាមរយៈវិធានការសំខាន់ៗ ដូចខាងក្រោម៖

- បន្តអនុវត្តគោលការណ៍បង្កើនបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ក្នុងគោលដៅលើកកម្ពស់ជីវភាពរស់នៅ, បង្កើនផលិតភាពការងារ និងពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដោយឈរលើគោលការណ៍សមធម៌, គុណាធិបតេយ្យ និងចីរភាពថវិកា,
- កំណត់គោលការណ៍ក្នុងការជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មី សម្រាប់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដែលត្រូវសមាមាត្រនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ លើកលែងតែក្រសួងអាទិភាព,
- បន្តតម្រង់ធនធានថវិកាសម្រាប់វិស័យគន្លឹះ ដែលនឹងធានាឱ្យបាននូវភាពធន់រឹងមាំប្រកបដោយបរិយាប័ន្ន និងចីរភាព តាមរយៈការផ្តល់អាទិភាពទៅលើការពង្រឹងរដ្ឋបាលសាធារណៈ, ការអភិវឌ្ឍធនធានមនុស្ស, ការកសាងហេដ្ឋារចនាសម្ព័ន្ធទាំងរូបវន្ត និងឌីជីថល, ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងការពង្រឹងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, ប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធសុខាភិបាល,
- បន្តកែលម្អគុណភាព និងភាពគ្រប់ជ្រុងជ្រោយនៃផែនការយុទ្ធសាស្ត្រថវិកា ដោយពង្រឹងការផ្សារភ្ជាប់ថវិកា ទៅនឹងគោលនយោបាយអាទិភាពតាមវិស័យ និងបន្តពង្រឹងការផ្សារភ្ជាប់ផែនការលទ្ធកម្មជាមួយនឹងគម្រោងថវិកាប្រចាំឆ្នាំ,
- បន្តអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ សំដៅធានាបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈ ដោយផ្តោតសំខាន់លើការវិនិយោគចំពោះវិស័យអាទិភាព ពិសេសវិស័យបង្កើនផលិតភាព, ជំរុញការតភ្ជាប់ និង លើកកម្ពស់សមត្ថភាពប្រកួតប្រជែង, និង
- បន្តជំរុញការអនុវត្តកម្មវិធីកែទម្រង់នានា និងគោលនយោបាយអាទិភាព ដែលរួមមាន ការពង្រឹង ក)-ការរៀបចំក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៣-២០២៥, ខ)-ការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥, គ)-ការអនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈឆ្នាំ ២០១៩-២០២៥, ឃ)-ការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ ២០២៤-២០២៨, ង)-ការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្ម

សាធារណៈឆ្នាំ ២០១៩-២០២៥ និង ច)-ការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ ២០១៩-២០២៥។

**២.២.២.៣-ក្របខ័ណ្ឌតុល្យភាពថវិកាឆ្នាំ ២០២៤**

២១-ជារួម ការអនុវត្តនូវវិធានការផ្នែកចំណូល និងផ្នែកចំណាយខាងលើនឹងជួយសម្រេចបាននូវអតិរេកថវិកាចរន្តស្មើនឹងប្រមាណ ៣,៨៩% នៃ ផ.ស.ស. និងឱនភាពថវិកាសរុបក្នុងរង្វង់ -៣,២២% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០២៤ ដើម្បីបង្កើនការវិនិយោគ និងបង្កើតតម្លៃបន្ថែមលើមូលដ្ឋានកំណើនសេដ្ឋកិច្ចដែលមានស្រាប់ ជាមួយនឹងការជំរុញឱ្យមានការវិនិយោគទៅលើប្រភពថ្មីនៃកំណើនដែលមានសក្តានុពលសេដ្ឋកិច្ច និងមានផលិតភាពខ្ពស់, ព្រមទាំងបន្តពង្រឹងសមត្ថភាពស្ថាប័ន និងលើកកម្ពស់សមត្ថភាពមន្ត្រី របបសោធនជូននិវត្តជន និងជំនួយសង្គមផ្សេងៗ ក៏ដូចជា ការបន្តដំឡើងបៀវត្សអប្បបរមាជូនមន្ត្រីរាជការ ដើម្បីលើកកម្ពស់សុខុមាលភាពសង្គម កសាងភាពធន់នៃសង្គមកម្ពុជា និងធានាសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សំខាន់ៗ ដែលមានចែងក្នុងរបៀបវារៈគោលនយោបាយនៅក្នុងឆ្នាំដំបូងនៃរាជរដ្ឋាភិបាល នីតិកាលទី ៧។

**៣-គោលការណ៍ និងបច្ចេកទេសនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៤-២០២៦**

២២-ក្រសួង-ស្ថាប័ននីមួយៗ ត្រូវផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ជាពិសេសពិតានចំណាយគោលសម្រាប់ក្រសួង-ស្ថាប័ននីមួយៗដូចបានកំណត់ខាងលើ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួនឱ្យបានល្អត្រឹមត្រូវតាមទិសដៅនេះ។ គួរកត់សម្គាល់ផងដែរថា ផែនការយុទ្ធសាស្ត្រថវិកា គឺជាឧបករណ៍ដ៏សំខាន់សម្រាប់៖ (១)-ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន និងគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល, (២)-បង្កើនវិចារណកម្មអាទិភាពចំណាយរបស់ក្រសួង-ស្ថាប័ន, (៣)-ធានានិរន្តរភាពនៃការអនុវត្តកម្មវិធីរបស់ក្រសួង-ស្ថាប័ន (៤)-ជាមូលដ្ឋានសម្រាប់ការពន្យល់ និងការបង្ហាញសេចក្តីសំអាងអំពីតម្រូវការថវិកាសម្រាប់ការងារអាទិភាព និង (៥)-ជាមូលដ្ឋានសម្រាប់ការរៀបចំ និងវិភាជថវិកាប្រចាំឆ្នាំឱ្យចំគោលដៅអាទិភាព។

២៣-ដូចនេះ, ក្រសួង-ស្ថាប័ននីមួយៗ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិការួមមួយ ដែលត្រូវគ្របដណ្តប់ទាំងថវិការដ្ឋបាលកណ្តាល, ថវិកាមន្ទីរជំនាញ រាជធានី-ខេត្ត និងថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលស្ថិតក្រោមឱវាទក្រសួង-ស្ថាប័ននោះ ព្រមទាំងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ដោយត្រូវធ្វើសមាហរណកម្មថវិកាចរន្ត និងថវិកាមូលធន ព្រមទាំងរវាងថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីធ្វើឱ្យផែនការយុទ្ធសាស្ត្រថវិកាមានគុណភាពកាន់តែល្អប្រសើរ ក៏ដូចជាជួយលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជ និងគ្រប់គ្រងថវិកាប្រចាំឆ្នាំ។ ក្នុងន័យនេះ, ដើម្បីធានាបាននូវផែនការយុទ្ធសាស្ត្រថវិកាប្រកបដោយគុណភាព និងភាពគ្រប់ជ្រុងជ្រោយ, *ក្រសួង-ស្ថាប័ននីមួយៗ ត្រូវជំរុញ និងលើកទឹកចិត្តដល់* ***ក្រុមការងារថវិកា*** *របស់ខ្លួនដែលមានសមាសភាពមកពីអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ឬ/និងថវិកា/គណនេយ្យ ដែលហៅថា* ***"អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ"****, អគ្គនាយកដ្ឋាន/នាយកដ្ឋានផែនការ, អង្គភាពថវិកា/អង្គភាពជំនាញ និងអង្គភាពគ្រប់គ្រងគម្រោងឱ្យដំណើរការដោយសកម្ម និងប្រកបដោយការទទួលខុសត្រូវខ្ពស់។*

២៤-ក្នុងន័យនេះ ក្រុមការងារថវិកាត្រូវខិតខំធានាឱ្យប្រាកដថា ទាំងធនធាន និងទាំងសកម្មភាពការងារទាំងអស់របស់ក្រសួង-ស្ថាប័នខ្លួន ត្រូវបានដាក់បញ្ចូល ឬឆ្លុះបញ្ចាំងក្នុងផែនការយុទ្ធសាស្ត្រថវិកា សំដៅធានាថាថវិកាត្រូវបានវិភាជត្រង់ទៅចំសកម្មភាព និងចំសេចក្តីត្រូវការយ៉ាងពិតប្រាកដរបស់អង្គភាពអនុវត្តសកម្មភាពរៀងៗខ្លួន ព្រមទាំងធានាបាននូវតុល្យភាពនៃការវិភាជថវិកា ហើយឆ្លើយតបបានជាអតិបរមាទៅនឹងគោលបំណងគោលនយោបាយ និងរវាងកម្មវិធីដែលបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា។ ដូចនេះ, ដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៤-២០២៦ ឱ្យមានលក្ខណៈឯកភាពគ្នាទាំងរចនាសម្ព័ន្ធ និងទាំងខ្លឹមសារ, ក្រសួង-ស្ថាប័ននីមួយៗ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន តាមទម្រង់ដូចមានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធទី ២។

២៥-ផ្អែកលើកញ្ចប់ថវិកាក្នុងកម្រិតពិតានចំណាយគោល ដែលត្រូវបានផ្តល់ជូនគ្រប់ក្រសួង-ស្ថាប័ន ដូចមានលម្អិតក្នុងផ្នែក ២.២ សម្រាប់រៀបចំផែនការយុទ្ធសាស្ត្រថវិកានេះ, ក្រសួង-ស្ថាប័នត្រូវធ្វើផែនការថវិការយៈពេលមធ្យម (៣ ឆ្នាំ) ដោយត្រូវគោរពតាមពិតានចំណាយគោលដែលបានផ្តល់ជូនសម្រាប់សកម្មភាពការងារ ឬគម្រោង ដែលត្រូវបន្តអនុវត្តក្នុងក្របខ័ណ្ឌដែលមិនមានការផ្លាស់ប្តូរខាងអាទិភាពគោលនយោបាយ។ ជាមួយគ្នានេះ, ក្រសួង-ស្ថាប័នត្រូវបានអនុញ្ញាតឱ្យគ្រោងនូវតម្រូវការធនធានថវិកាសម្រាប់អនុវត្តគោលនយោបាយថ្មីៗ ដែលទើបមានការសម្រេចពីរាជរដ្ឋាភិបាលនៅក្នុងឆ្នាំអនុវត្តថវិកានេះ។

២៦-ជាមួយគ្នានេះដែរ, ក្រសួង-ស្ថាប័ន ត្រូវកំណត់ **អង្គភាពទទួលខុសត្រូវ** ដែលហៅថា **អង្គភាពថវិកា** និង អ្នកគ្រប់គ្រង ទៅតាមកម្រិតនៃរចនាសម្ព័ន្ធកម្មវិធី (កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព)។ ដើម្បីពង្រឹងការអនុវត្ត *អនុក្រឹត្យលេខ ២៤២ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០២១ ស្តីពីការបង្កើនចំនួនអង្គភាពថវិកា និង ការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនអង្គភាពថវិកា* ប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់, នៅក្នុងអំឡុងនៃការរៀបចំគម្រោងថវិកាឆ្នាំ ២០២៤ របស់ខ្លួននេះ *ក្រសួង-ស្ថាប័ន ត្រូវដាក់ចេញនូវផែនការច្បាស់លាស់ ក្នុងការបង្កើនចំនួនអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញសម្រាប់ការអនុវត្តនៅឆ្នាំ ២០២៤, ឆ្នាំ ២០២៥ និងឆ្នាំ ២០២៦*។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងផ្តល់កិច្ចសហការ ផ្នែកបច្ចេកទេសលើការពិនិត្យ និងវាយតម្លៃអំពីលក្ខណៈវិនិច្ឆ័យរបស់អង្គភាពដែលអាចនឹងត្រូវបង្កើតជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ ឬអង្គភាពថវិកា ដែលអាចនឹងប្រែក្លាយជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ព្រមទាំងផ្តល់ការបណ្តុះបណ្តាលសមត្ថភាពផ្នែកថវិកា និងនីតិវិធីហិរញ្ញវត្ថុ ដល់អង្គភាពថវិកា តាមការស្នើសុំពីក្រសួង-ស្ថាប័នសាមីនីមួយៗ។

## ៣.១-ការគ្រោងចំណូលថវិកាសម្រាប់ឆ្នាំ ២០២៤-២០២៦

២៧-ការគ្រោងចំណូល គឺត្រូវគ្រោងសម្រាប់រយៈពេល ៣ ឆ្នាំ ២០២៤-២០២៦ ដោយរួមទាំងចំណូលថវិការដ្ឋដែលស្ថិតក្រោមការគ្រប់គ្រង និងប្រមូលផ្ទាល់ដោយក្រសួង-ស្ថាប័ន និងចំណូលដែលបានមកពីហិរញ្ញប្បទានសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ និងប្រភពផ្សេងៗទៀត។ ក្នុងការគ្រោងចំណូល ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវផ្តោតការយកចិត្តទុកដាក់លើចំណុចសំខាន់ៗដូចខាងក្រោម៖

- គោលដៅសូចនាករចំណូលនៃក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលបានដាក់ចេញនៅក្នុងសារាចរនេះ
- ការវាយតម្លៃការអនុវត្តការប្រមូលចំណូលក្នុងឆ្នាំកន្លងទៅ និងការប៉ាន់ស្មានការអនុវត្តប្រមូលចំណូលក្នុងឆ្នាំកំពុងអនុវត្ត
- ការដាក់ចេញវិធានការដាក់ស្តែងបន្ថែមទៀតតាមក្រសួង-ស្ថាប័ននីមួយៗ ដើម្បីបង្កើនការប្រមូលចំណូល ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។

ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំផ្នែកនេះទៅតាម **តារាងគំរូដែលភ្ជាប់ជាមួយសារាចរនេះ**។ នៅក្នុងផ្នែកនេះ ចំពោះក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ដែលមិនមានប្រភពចំណូល គឺពុំតម្រូវឱ្យរៀបចំឡើយ។

ទន្ទឹមនេះ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានប្រភពចំណូល គឺត្រូវដាក់ចេញវិធានការដាក់ស្តែងបន្ថែមទៀតតាមក្រសួង-ស្ថាប័ននីមួយៗ សម្រាប់ពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។ *ផ្ទុយទៅវិញ, ការគ្រោងចំណូលមិនអស់សក្តានុពលដែលមាន គឺជាកម្មវត្ថុនៃការរឹតត្បិតចំណាយនៅក្នុងកិច្ចប្រជុំចរចាកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់ក្រសួង-ស្ថាប័ន ដែលមានភារកិច្ចប្រមូលចំណូល។*

## ៣.២-ការគ្រោងចំណាយថវិកាសម្រាប់ឆ្នាំ ២០២៤-២០២៦

២៨-ការគ្រោងតម្រូវការចំណាយ គឺជាការគណនាចំណាយសម្រាប់រយៈពេល ៣ ឆ្នាំ ២០២៤-២០២៦ ទៅតាមកម្មវិធីនីមួយៗ និងទៅតាមប្រភេទចំណាយ និងប្រភពធនធាន ទាំងថវិកាជាតិ និងទាំងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ។ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវរៀបចំខ្លឹមសារនៃផ្នែកទី ៥ នេះ **តាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរនេះ**។

ក្នុងការគណនាអំពីតម្រូវការថវិកា ដើម្បីអនុវត្តកម្មវិធីនីមួយៗ ត្រូវផ្តោតការយកចិត្តទុកដាក់លើចំណុចសំខាន់ៗ ដូចខាងក្រោម៖

ទី១-ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈដែលរាជរដ្ឋាភិបាលបានដាក់ចេញ តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលរួមមានគោលដៅសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ដូចជា កំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ អត្រាអតិផរណាប្រចាំឆ្នាំ និងគោលដៅសូចនាករចំណាយ ព្រមជាមួយនឹងគោលនយោបាយអាទិភាពចំណាយ ទាំងផ្នែកចំណាយចរន្ត និងចំណាយមូលធន (ឬហៅថា ចំណាយវិនិយោគ)។ ក្នុងន័យនេះ ***ពិតានចំណាយគោលនៃចំណាយចរន្តរបស់ក្រសួង-ស្ថាប័ន ត្រូវបានផ្តល់ជាកញ្ចប់ថវិកាសម្រាប់រយៈពេល ៣ ឆ្នាំ (២០២៤-២០២៦) ទាំងផ្នែកចំណាយបន្ទុកបុគ្គលិក (ដោយមិនគិតបញ្ចូលនូវរង្វាន់ពីសេវាសាធារណៈ) និងចំណាយមិនមែនបន្ទុកបុគ្គលិកទៅតាមគោលការណ៍ដែលលម្អិតនៅក្នុងផ្នែក ២.៣*** ។ ទន្ទឹមនេះ, ក្រសួងចំនួន ៩ ដែលទទួលបានកញ្ចប់ចំណាយវិនិយោគជាប្រចាំ ក៏ទទួលបានកញ្ចប់ពិតានចំណាយគោលនៃចំណាយមូលធនសម្រាប់គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាជាតិ និងហិរញ្ញប្បទានសហប្រតិបត្តិការដោយដៃគូអភិវឌ្ឍផងដែរ។

ទី២-ការវាយតម្លៃអំពីសមត្ថភាពក្នុងការអនុវត្តចំណាយក្នុងពេលកន្លងមក និងការប៉ាន់ស្មានសមត្ថភាពអនុវត្តចំណាយក្នុងឆ្នាំ ២០២៣ ដែលក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត គ្រឹះស្ថានសាធារណៈរដ្ឋបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ បាននិងកំពុងអនុវត្ត,

ទី៣-ការកំណត់តម្រូវការថវិកាតាមឆ្នាំនីមួយៗ ត្រូវគណនាចំណាយប្រកបដោយសុក្រឹតភាពតាមតម្រូវការជាក់ស្តែងនៃកម្មវិធីនីមួយៗ ដោយត្រូវគិតគូរឈរលើ**ទិដ្ឋភាព** ៣ គឺ៖

- ផែនការសកម្មភាព ឬសកម្មភាពការងារដែលមានស្រាប់ដែលត្រូវបន្តអនុវត្ត ដើម្បីសម្រេចគោលនយោបាយរបស់ក្រសួង-ស្ថាប័នរៀងខ្លួន,
- ផែនការសកម្មភាព ឬសកម្មភាពការងារដែលមានលក្ខណៈបញ្ចប់ត្រឹមមួយឆ្នាំ, និង
- ផែនការសកម្មភាព ឬសកម្មភាពការងារថ្មី ដើម្បីសម្រេចគោលនយោបាយរបស់ក្រសួង-ស្ថាប័នរៀងខ្លួន។

ដូច្នេះ ផ្អែកលើគោលការណ៍ទាំងបីខាងលើនេះ គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទទាំងអស់ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវគ្រោងតម្រូវការចំណាយសម្រាប់ឆ្នាំ ២០២៤-២០២៦ តាមគោលការណ៍នៃការកំណត់កញ្ចប់ថវិកា ដូចខាងក្រោម៖

• **ចំណាយបន្ទុកបុគ្គលិក** (ជំពូក ៦៤)៖ រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា នឹងនៅបន្តផ្តល់ការយកចិត្តទុកដាក់ខ្ពស់ដល់ការលើកកម្ពស់ជីវភាពរបស់មន្ត្រីរាជការឱ្យកាន់តែល្អប្រសើរថែមទៀត។ ដូចនេះ, **សម្រាប់ឆ្នាំ ២០២៤**, ក្រសួង-ស្ថាប័ននីមួយៗ ត្រូវគ្រោងចំណាយបន្ទុកបុគ្គលិកទៅតាមគោលការណ៍ណែនាំលម្អិត សម្រាប់ការជ្រើសរើសចំនួនក្របខ័ណ្ឌថ្មី និងការដំឡើងបៀវត្សអប្បបរមាជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ, និងសម្រាប់ការកំណត់ចំនួន និងការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែជូនមន្ត្រីជាប់កិច្ចសន្យា ព្រមទាំងសម្រាប់ការផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីចូលឆ្នាំថ្មីប្រពៃណីជាតិ និងបុណ្យភ្ជុំបិណ្ឌ ជូនដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំងនិវត្តជន និងជនបាត់បង់ សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ស្របតាមគោលការណ៍លម្អិតដែលមានចែងក្នុង**ចំណុច (ក) នៃផ្នែក ៤.២-អំពីការគ្រោងចំណាយបន្ទុកបុគ្គលិកឆ្នាំ ២០២៤**។ ដោយឡែក, សម្រាប់គម្រោងចំណាយបន្ទុកបុគ្គលិកឆ្នាំ ២០២៥ និងឆ្នាំ ២០២៦ ត្រូវគ្រោងក្នុងកម្រិតក្របខ័ណ្ឌ និងកម្រិតបៀវត្សដែលបានគ្រោងសម្រាប់ឆ្នាំ ២០២៤ និងឆ្នាំ ២០២៥ រៀងៗគ្នា ហើយចំនួនក្របខ័ណ្ឌថ្មី យ៉ាងច្រើនត្រូវស្មើនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬលាឈប់ពីក្របខ័ណ្ឌរដ្ឋ និងមរណភាពដែលត្រូវកាត់ចេញពីអង្គភាពសាមី។

ជាមួយគ្នានេះ សម្រាប់ឆ្នាំ ២០២៤ រាជរដ្ឋាភិបាលបានគិតគូរផងដែរលើការដំឡើងប្រាក់សោធនជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ដែលគោលការណ៍លម្អិតសម្រាប់អនុវត្តនឹងត្រូវកំណត់ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល។

• **ចំណាយក្រៅបន្ទុកបុគ្គលិក** (ជំពូក ៦០ ការទិញ, ជំពូក ៦១ សេវាកម្ម, ជំពូក ៦២ អត្ថប្រយោជន៍សង្គម, ជំពូក ៦៥ ឧបត្ថម្ភធន)៖ ត្រូវគ្រោងតាមគោលការណ៍ ដូចខាងក្រោម៖

- ក្រសួង-ស្ថាប័ននៅរដ្ឋបាលកណ្តាលៈ ត្រូវគ្រោងថវិកាទៅតាមទំហំពិតានចំណាយគោលឆ្នាំ ២០២៤-២០២៦ ប៉ុន្តែ កញ្ចប់ថវិកាតាមពិតានចំណាយគោលនេះនឹងមិនទទួលបានជាស្វ័យប្រវត្តិនោះទេ គឺនៅជាកម្មវត្ថុនៃការពិនិត្យ និងពិភាក្សា ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការរិភាជថវិកា និងប្រតិបត្តិការចំណាយ។ ទន្ទឹមនេះ, រាល់ការគ្រោងចំណាយទាំងអស់ត្រូវភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធ រួមមានៈ ការសិក្សា, វិភាគ, វាយតម្លៃ និងការផ្តល់អំណះអំណាងត្រឹមត្រូវ និងច្បាស់លាស់ ទើបអាចដាក់ជាកម្មវត្ថុនៃការពិចារណា និងពិភាក្សាចរចា នៅពេលរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំបាន។

- **មន្ទីរជំនាញរាជធានី-ខេត្តនៃក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត** (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល)៖ ផ្អែកលើទំហំពិតានចំណាយគោលរួមដែលផ្តល់ជូនដល់មន្ទីរជំនាញរាជធានី-ខេត្ត, ត្រូវគ្រោងយ៉ាងច្រើនបំផុតស្មើនឹងកម្រិតថវិកាអតិបរមានៃទំហំពិតានចំណាយគោល។ ប៉ុន្តែត្រូវកត់សម្គាល់ថា **កញ្ចប់ថវិកាដែលគ្រោងផ្តល់នេះ មិនទទួលបានជាស្វ័យប្រវត្តិទេ គឺតម្រូវឱ្យមន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលរាជធានី-ខេត្តនីមួយៗ ដែលទទួលបាននូវការប្រគល់មុខងារពីក្រសួងសុខាភិបាល** ត្រូវផ្តល់ឯកសារពាក់ព័ន្ធដែលមានការសិក្សា វិភាគ វាយតម្លៃ និងអំណះអំណាងត្រឹមត្រូវ និងច្បាស់លាស់ ព្រោះការគ្រោងចំណាយត្រូវកាត់ចេញមុខចំណាយលើសកម្មភាពការងារដែលត្រូវបានបញ្ចប់ ពិសេសចំណាយមិនប្រចាំ ដើម្បីសន្សំសំចៃសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់ តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

- ដោយឡែក សម្រាប់មុខងារមានភ្ជាប់លក្ខខណ្ឌក្នុងវិស័យអប់រំ ការគ្រោងកញ្ចប់ថវិកាត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងស្តីពីលក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុ សម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុងស្រុកទាំង ១៤ ក្នុងខេត្តបាត់ដំបង សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ។

- **គ្រឹះស្ថានសាធារណៈរដ្ឋបាលនៃក្រសួង-ស្ថាប័ននីមួយៗ** ត្រូវបានគ្រោងផ្តល់កញ្ចប់ថវិកាឧបត្ថម្ភធនសម្រាប់រយៈពេល ៣ ឆ្នាំ (ឆ្នាំ២០២៤-២០២៦) **ប៉ុន្តែកញ្ចប់ឧបត្ថម្ភធនដែលគ្រោងផ្តល់នេះ មិនទទួលបានជាស្វ័យប្រវត្តិទេ** គឺតម្រូវឱ្យគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ ត្រូវផ្តល់ការពន្យល់ និងអំណះអំណាងត្រឹមត្រូវ និងច្បាស់លាស់នូវស្ថានភាពចំណូលផ្ទៃក្នុងរបស់គ្រឹះស្ថាន និង ម្យ៉ាងទៀត, ក៏ត្រូវកាត់ចេញនូវទំហំចំណាយសម្រាប់សកម្មភាពដែលត្រូវបានបញ្ចប់ ជាពិសេសចំណាយមិនប្រចាំដើម្បីសន្សំសំចៃ ក៏ដូចជាសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់។

• **ចំណាយមូលធនសម្រាប់គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាជាតិ** (ជំពូក២១)៖ ត្រូវបានផ្តល់ជាពិតានចំណាយគោលសម្រាប់ក្រសួង-ស្ថាប័នចំនួន ៩ រួមមានៈ ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងមហាផ្ទៃ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងសុខាភិបាល, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ ពាក់ព័ន្ធនឹងវិស័យផ្លូវថ្នល់, ធារាសាស្ត្រ, អប់រំ, សុខាភិបាល និងវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសុខាភិបាល និងក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈ ត្រូវរៀបចំផែនការវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល ជាបញ្ជីគម្រោងសម្រាប់ឆ្នាំ ២០២៤-២០២៦ ដើម្បីជាមូលដ្ឋានសម្រាប់ធ្វើសមាហរណកម្មគម្រោងចំណាយវិនិយោគ ជាមួយនឹងគម្រោងចំណាយចរន្តនៅកម្រិត

កម្មវិធី និងអនុកម្មវិធី និងដោយភ្ជាប់ជាមួយនូវបញ្ជីគម្រោងដែលបានរៀបចំ។ ចំពោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នឹងត្រូវបន្តអនុវត្តរៀបចំផែនការវិនិយោគសាធារណៈ ៣ ឆ្នាំ រំកិល ដើម្បីត្រៀមលក្ខណៈចាប់ផ្តើមធ្វើសមាហរណកម្មគម្រោងចំណាយវិនិយោគតាមការចាំបាច់ នៅឆ្នាំខាងមុខ ជាមួយនឹងគម្រោងចំណាយចរន្ត នៅកម្រិតកម្មវិធី និងអនុកម្មវិធី។ ទោះយ៉ាងនេះក្តី, ក្រសួងទាំង ៩ ខាងលើនេះ នឹងមិនទទួលបានកញ្ចប់ចំណាយវិនិយោគជាស្វ័យប្រវត្តិទេ, ការធ្វើអាទិភាវូបនីយកម្មគម្រោង និងការផ្តល់ថវិកា គឺជាកម្មវត្ថុនៃការពិនិត្យពិភាក្សាតាមយន្តការគណៈកម្មការ ឬក្រុមការងារអន្តរក្រសួង។ ចំពោះក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀតដែលមានតម្រូវការចំណាយវិនិយោគ ក៏ត្រូវចាប់ផ្តើមសិក្សារៀបចំផែនការវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល ឱ្យច្បាស់លាស់ និងរៀបចំលើកសំណើគម្រោងក្នុងកម្រិតទំហំថវិកាសមស្រប ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរៀបចំធ្វើអាទិភាវូបនីយកម្មគម្រោងតាមការចាំបាច់ ហើយគោរពស្នើសុំប្រមុខរាជរដ្ឋាភិបាល ពិនិត្យសម្រេចតាមលទ្ធភាពថវិកា និងតាមវិធានការផ្នែកចំណាយដែលបានកំណត់នៅផ្នែកខាងលើនៃសារាចរនេះ។

- **ចំណាយមូលធន/វិនិយោគដោយហិរញ្ញប្បទានសហប្រតិបត្តិការដោយដៃគូអភិវឌ្ឍ៖** ត្រូវបានផ្តល់ជាពិតានចំណាយគោលសម្រាប់ក្រសួង-ស្ថាប័នចំនួន ៩ ដូចចំណាយមូលធនថ្នាក់ជាតិខាងលើដែរ។ ចំពោះ ក្រសួង-ស្ថាប័នដទៃទៀត ដែលបាននិងកំពុងទទួលបានហិរញ្ញប្បទានសហប្រតិបត្តិការ ឬគ្រោងនឹងទទួលបានហិរញ្ញប្បទានស្របតាមកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល (២០២៤-២០២៦) ត្រូវគ្រោងឱ្យបានត្រឹមត្រូវទៅតាមកិច្ចព្រមព្រៀង ឬអនុស្សរណៈនៃការយោគយល់គ្នា ឬការសន្យាតាមរយៈយន្តការផ្សេងៗ។

## ៤-គោលការណ៍ និងបច្ចេកទេសនៃការរៀបចំថវិកាឆ្នាំ ២០២៤

ផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដូចបានកំណត់ខាងលើ ក្រសួង-ស្ថាប័ននីមួយៗ ត្រូវគ្រោងចំណូល-ចំណាយ ដូចខាងក្រោម៖

### ៤.១-ការគ្រោងចំណូលថវិកាឆ្នាំ ២០២៤

២៩-ការគ្រោងគិតចំណូលថវិកាចរន្ត អាស្រ័យលើប្រភពធនធាននៃផលិតផល ឬផលទុន ដែលជាប្រភពចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។ ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច និងលក្ខខណ្ឌនៃប្រភពធនធានដូចបានលើកឡើងខាងលើ, ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំគម្រោងចំណូលថវិការបស់ខ្លួន ដូចតទៅ៖

- ចំណូលសារពើពន្ធ ត្រូវគិតគូរដោយផ្អែកលើមូលដ្ឋាន ដូចខាងក្រោម៖
  - លទ្ធផលដែលសម្រេចនៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ (ឆ្នាំ ២០២៣);
  - ចំណូលបន្ថែមដែលសង្ឃឹមថានឹងប្រមូលបាន ដោយសារការពង្រឹង និងកែលម្អរដ្ឋបាល និងគោលនយោបាយពន្ធដារ គោលនយោបាយគយនិងរដ្ឋាករ ការធ្វើវិចារណកម្មសារពើពន្ធ និងការប្រមូលបំណុលពន្ធដែលត្រូវទារ;
  - ការប៉ាន់ស្មានលើការអភិវឌ្ឍសេដ្ឋកិច្ច និងអាជីវកម្មនៅពេលខាងមុខ;
  - ការប្រែប្រួលដែលអាចកើតមានឡើង ព្រមទាំងការត្រួតពិនិត្យ និងពិចារណាទៅលើអត្រានិងមូលដ្ឋានប្រមូលពន្ធ។

- ចំពោះចំណូលមិនមែនសារពើពន្ធ ត្រូវគិតគូរទៅតាមគោលការណ៍ដែលនាំឱ្យមានផលទុន ដូចជា កិច្ចសន្យាសម្បទានគ្រប់ប្រភេទ កិច្ចសន្យាជួលសេវាកម្ម ការពង្រឹងនិងកែលម្អការគ្រប់គ្រងទ្រព្យ-សម្បត្តិរដ្ឋ ព្រមទាំងការប្រមូលបំណុលដែលត្រូវទារជាដើម ។ល។

## ៤.២- ការគ្រោងចំណាយថវិកាឆ្នាំ ២០២៤

៣០-ថវិកាព័ត៌មានសមិទ្ធកម្ម ឬហៅកាត់ថា "ថវិកាសមិទ្ធកម្ម" ព្រមជាមួយនឹងកិច្ចព្រមព្រៀងសមិទ្ធកម្ម ត្រូវបានដាក់ឱ្យអនុវត្តសាកល្បងចាប់ពីឆ្នាំ ២០២៣។ ដូចនេះ, ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារបានប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវផ្តោតការយកចិត្តទុកដាក់ឱ្យកាន់តែខ្លាំងលើការកំណត់លទ្ធផល ឬធាតុចេញ (Output) ដែលនឹងត្រូវសម្រេចបាន។ ក្នុងន័យនេះ, ក្រសួង-ស្ថាប័នត្រូវពង្រឹងបន្ថែមនូវប្រសិទ្ធភាព នៃការគ្រោងថវិកាទៅតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ដែលជាមូលដ្ឋានដ៏សំខាន់សម្រាប់ការពិភាក្សាចរចាថវិកា ក៏ដូចជាសម្រាប់ធ្វើវិមជ្ឈការសិទ្ធិអំណាចនៃការអនុវត្តចំណាយផងដែរ។ លើសពីនេះ ក្រសួង-ស្ថាប័ន ក៏ត្រូវកែលម្អរចនាសម្ព័ន្ធកម្មវិធី និងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់ខ្លួនឱ្យកាន់តែស៊ីសង្វាក់គ្នា និងមានលក្ខណៈ សមាហរណកម្មក្នុងកម្រិតវិស័យ, ម្យ៉ាង, ដើម្បីសម្រេចបានលទ្ធផលល្អ និងមានការទទួលខុសត្រូវកាន់តែច្បាស់លាស់ និង ម្យ៉ាងទៀត, ដើម្បីសម្រួលដល់ការអនុវត្តឱ្យកាន់តែរលូនល្អផងដែរ។ ជាមួយគ្នានេះ, *ក្រសួង-ស្ថាប័ន ត្រូវយកចិត្តទុកដាក់ក្នុងការកំណត់គោលបំណង និងកត្តាកំណត់ជោគជ័យនៃកម្មវិធី និងអនុកម្មវិធីឱ្យបានល្អ ដើម្បីធានាបាននូវការផ្សារភ្ជាប់ថវិកាទៅនឹងគោលបំណងគោលនយោបាយ ពិសេសត្រូវកំណត់សូចនាករ និងគោលដៅសូចនាករឱ្យបានត្រឹមត្រូវ និងច្បាស់លាស់។*

៣១-កិច្ចព្រមព្រៀងសមិទ្ធកម្ម ត្រូវបានកំណត់ជា ៣ កម្រិត៖ *(ទី១)-រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួង-ស្ថាប័នសាមី, (ទី២)-រវាងរដ្ឋមន្ត្រីក្រសួង-ស្ថាប័ន ជាមួយនឹងអ្នកគ្រប់គ្រងកម្មវិធីនៅតាមក្រសួង-ស្ថាប័នសាមី, និង (ទី៣)-រវាងអ្នកគ្រប់គ្រងកម្មវិធីជាមួយនឹងប្រធានអង្គភាពថវិកា* ***ដូចមានភ្ជាប់ជូននូវគំរូកិច្ចព្រមព្រៀងសមិទ្ធកម្មទាំង ៣ កម្រិតនេះ។*** *សម្រាប់ការរៀបចំថវិកាឆ្នាំ ២០២៤ ខាងមុខនេះ, ក្រសួង-ស្ថាប័នសរុបចំនួន ១៧ ត្រូវបានកំណត់ឱ្យអនុវត្តសាកល្បងកិច្ចព្រមព្រៀងសមិទ្ធកម្មនេះ ក្នុងនោះក្រសួង-ស្ថាប័នចំនួន ១០ បន្ថែមថ្មី ដែលរួមមាន៖ ក្រសួងពាណិជ្ជកម្ម, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងបរិស្ថាន, ក្រសួងកិច្ចការនារី, ក្រសួងផែនការ, ក្រសួងមុខងារសាធារណៈ, ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងក្រសួងធម្មការ និងសាសនា ហើយក្រសួង-ស្ថាប័នចំនួន ៧ ដែលត្រូវអនុវត្តបន្តពីឆ្នាំកន្លងមក រួមមាន៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសុខាភិបាល និង ក្រសួងយុត្តិធម៌។*

៣២-គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ព្រមទាំង រដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារបានប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យ អប់រំ) ត្រូវរៀបចំគម្រោងចំណាយដែលឆ្លុះបញ្ចាំងលម្អិតតាមមាតិកាសេដ្ឋកិច្ចនៃចំណាត់ថ្នាក់ថវិកា (ជំពូកគណនី និង អនុគណនី) ព្រមទាំងត្រូវវិភាគឱ្យបានច្បាស់លាស់អំពីតម្រូវការចំណាយតាមចង្កោមសកម្មភាព អនុកម្មវិធី និង កម្មវិធី និងត្រូវភ្ជាប់មកជាមួយនូវឯកសារសម្រាប់គាំទ្រ រួមទាំងឯកសារអង្កេត ឬវិភាគតាមការចាំបាច់ ព្រមទាំង

ពន្យល់បញ្ជាក់អំពីភាពចាំបាច់នៃតម្រូវការចំណាយលើសកម្មភាពការងារនីមួយៗឱ្យបានគ្រប់ជ្រុងជ្រោយ ហើយឯកសារទាំងនេះ ក៏ជាកម្មវត្ថុសម្រាប់ការត្រួតពិនិត្យ ពិភាក្សា និងចរចាថវិកាផងដែរ។ លើសពីនេះ, ការគណនាតម្រូវការចំណាយត្រូវផ្អែកលើកត្តាដែលទាក់ទងនឹងមុខសញ្ញាចំណាយ ដូចជា ចំណាយបន្ទុកបុគ្គលិក និងចំណាយមិនមែនបន្ទុកបុគ្គលិក ដែលត្រូវប៉ាន់ស្មានតម្លៃជាតុចូលដែលត្រូវការជាក់ស្តែង ដោយធៀបនឹងតម្រូវការប្រើប្រាស់ក្នុងឆ្នាំ ២០២២ និងការប៉ាន់ស្មាននៃការអនុវត្តក្នុងឆ្នាំ ២០២៣ និងដោយផ្អែកលើថ្លៃឯកតានៃទីផ្សារ ឬតាមគោលរបបកំណត់ជាដើម។

៣៣-ឈរលើមូលដ្ឋានតម្រូវការចំណាយ ដែលបានប៉ាន់ស្មានក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៤-២០២៦ ក្នុងកម្រិតនៃទំហំពិតានចំណាយគោលដែលបានផ្តល់ជូនគ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារបានប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ), **ក្នុងការរៀបចំគម្រោងចំណាយថវិកាឆ្នាំ ២០២៤ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារបានប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវគ្រោងចំណាយរបស់ខ្លួនទៅតាមគោលការណ៍** និងបណ្តាវិធានការ ដូចខាងក្រោម៖

**ក-ចំណាយបន្ទុកបុគ្គលិក(ជំពូក ៦៤)៖** នាយកដ្ឋានបុគ្គលិកដែលជាសេនាធិការរបស់ក្រសួង-ស្ថាប័ននីមួយៗ ត្រូវសម្របសម្រួល និងគ្រោងចំណាយបន្ទុកបុគ្គលិកឱ្យបានសុក្រឹតតាមគោលការណ៍ ព្រមជាមួយនឹងការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងការប្រើប្រាស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ពោលគឺត្រូវចៀសវាងការគ្រោងបៀវត្ស ឬបន្ទុកពាក់ព័ន្ធនឹងបុគ្គលិកនេះទុកចោល។ ក្នុងន័យនេះ, ការគ្រោងចំណាយបន្ទុកបុគ្គលិកសម្រាប់ឆ្នាំ ២០២៤ ត្រូវអនុវត្តគោលការណ៍លម្អិត ដូចខាងក្រោម៖

- **ចំនួនក្របខ័ណ្ឌថ្មី** ត្រូវគ្រោងយ៉ាងច្រើនស្មើនឹងចំនួនមន្ត្រីចូលនិវត្តន៍, លាឈប់ពីក្របខ័ណ្ឌរដ្ឋ និងមរណភាព ដែលត្រូវបានកាត់ចេញពីអង្គភាពសាមី នៅក្នុងឆ្នាំ ២០២៣ និងត្រូវបញ្ជាក់អំពីគោលដៅនៃតម្រូវការ និងមុខងារនៃមន្ត្រីដែលត្រូវជ្រើសរើសបន្ថែមនេះ។ ជាមួយគ្នានេះ, មន្ត្រីដែលព្យួរការងារ និងមន្ត្រីដែលចូលបម្រើការងារវិញ ក៏ជាកម្មវត្ថុនៃការគ្រប់គ្រងឱ្យបានត្រឹមត្រូវ និងហ្មត់ចត់ផងដែរ។ លើសពីនេះ, *ក្នុងករណីការជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មី មានចំនួនតិចជាងចំនួនមន្ត្រីចូលនិវត្តន៍ លាឈប់ពីក្របខ័ណ្ឌរដ្ឋ និងមរណភាព, ក្រសួង-ស្ថាប័ន អាចស្នើសុំប្រើប្រាស់ថវិកានោះ ដើម្បីផ្តល់ការលើកទឹកចិត្តដល់មន្ត្រីដែលមានគុណវុឌ្ឍិ* ***និងសមត្ថភាពជំនាញខ្ពស់*** *និង/ឬ សម្រាប់បន្ថែមចំណាយមិនមែនបន្ទុកបុគ្គលិក ដើម្បីជាប្រយោជន៍សម្រាប់អង្គភាពរបស់ខ្លួន ពិសេសសម្រាប់ការងារដែលមានចរិតយុទ្ធសាស្ត្រក្នុងការកែទម្រង់ និងសម្រេចគោលនយោបាយសំខាន់ៗរបស់ក្រសួង-ស្ថាប័ន។*
- គ្រោងដំឡើង**បៀវត្សមូលដ្ឋាន**ចំនួន ៥% គិតចាប់ពីខែ មករា ដល់ខែ ធ្នូ ដោយត្រូវដំឡើងតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានពី ២ ៥០០ រៀល ក្នុង ១ ឯកតាសន្ទស្សន៍ នៅឆ្នាំ ២០២៣ ទៅ ២ ៦៣០ រៀល ក្នុង ១ ឯកតាសន្ទស្សន៍ នៅឆ្នាំ ២០២៤។
- គ្រោងដំឡើងប្រាក់បំណាច់មុខងារជូនមន្ត្រីរាជការស៊ីវិល ដោយផ្តល់បន្ថែមជូន ២២ ៥០០ រៀល សម្រាប់មន្ត្រីរាជការស៊ីវិលដែលមានប្រាក់បំណាច់មុខងារក្នុងកម្រិតចាប់ពី ១ ១៣០ ០០០ រៀល

ចុះក្រោម និងបន្ថែមជូន ២០ ០០០ រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារក្នុងកម្រិតចាប់ពី ១ ១៣០ ១០០ រៀល **ឡើងទៅ** និងជូនមន្ត្រីនគរបាលជាតិ និងយោធិន ដោយផ្តល់បន្ថែមជូន ២៥ ០០០ រៀល សម្រាប់មន្ត្រីនគរបាលជាតិ និងយោធិន ដែលមានប្រាក់បំណាច់មុខងារក្នុងកម្រិតចាប់ពី ៩៦០ ០០០ រៀល ចុះក្រោម និងបន្ថែមជូន ២០ ០០០ រៀល សម្រាប់មន្ត្រីនគរបាលជាតិ និងយោធិន ដែលមានប្រាក់បំណាច់មុខងារក្នុងកម្រិតចាប់ពី ៩៦០ ១០០ រៀល **ឡើងទៅ** ដោយគិតចាប់ពីខែ មេសា ដល់ខែ ធ្នូ។

- គ្រោងប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីចូលឆ្នាំថ្មីប្រពៃណីជាតិចំនួន **៥ ម៉ឺនរៀល** ក្នុងម្នាក់ និងក្នុងឱកាសបុណ្យភ្ជុំបិណ្ឌចំនួន **៥ ម៉ឺនរៀល** ក្នុងម្នាក់ ជូនដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំងនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន និង
- គ្រោងចំនួនមន្ត្រីជាប់កិច្ចសន្យាមិនឱ្យលើសពីចំនួន ដែលក្រសួងមុខងារសាធារណៈផ្តល់ជូនក្នុងឆ្នាំ ២០២៣ ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ចំពោះមន្ត្រីជាប់កិច្ចសន្យាត្រូវគ្រោង**ដំឡើងពី ៧១០ ០០០ រៀល ទៅដល់ ៧៧០ ០០០ រៀល** ដោយគិតចាប់ពីខែ មករា ដល់ខែ ធ្នូ។

ជាមួយគ្នានេះ សម្រាប់ឆ្នាំ ២០២៤, រាជរដ្ឋាភិបាលបានត្រៀមបម្រុងកញ្ចប់ថវិកាចំនួន ១០០ ប៊ីលានរៀល សម្រាប់ដំឡើងប្រាក់សោធនជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ជាពិសេសគិតគូរកាត់បន្ថយគម្លាតប្រាក់សោធនរវាងអ្នកចូលនិវត្តន៍ចាស់ និងថ្មី។ គោលការណ៍លម្អិតសម្រាប់អនុវត្តនឹងត្រូវកំណត់ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល។

**ខ-ចំណាយក្រៅបន្ទុកបុគ្គលិក (ជំពូក ៦០ ការទិញ, ជំពូក ៦១ សេវាកម្ម, ជំពូក ៦២ អត្ថប្រយោជន៍សង្គម, ជំពូក ៦៥ ឧបត្ថម្ភធន)៖** *គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារបានប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខា ភិបាល និងវិស័យអប់រំ) ត្រូវបានផ្តល់ការលើកទឹកចិត្តឱ្យធ្វើការកែលម្អមុខសញ្ញាចំណាយចាស់ៗ ដោយលុបចោល មុខសញ្ញាចំណាយមិនចាំបាច់ និងមិនសូវចាំបាច់ ដើម្បីបង្កើតមុខសញ្ញាចំណាយថ្មី ឬសកម្មភាពថ្មី ដែលបម្រើឱ្យកម្មវិធីកែទម្រង់ថ្មីៗ ដែលមានលក្ខណៈកាន់តែស៊ីជម្រៅ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងទ្រទ្រង់វិស័យចទ្ទល់កំណើនសេដ្ឋកិច្ចដែលមានស្រាប់ និងបង្កើតវិស័យចទ្ទល់កំណើនសេដ្ឋកិច្ចថ្មីៗ។* ដូចនេះ, ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវគ្រោងតាមគោលការណ៍នៃការកំណត់កញ្ចប់ថវិកា និងគណនាតម្រូវការចំណាយនៃជំពូកនីមួយៗ ដូចខាងក្រោម៖

- *<u>កំណត់ចំណាយជាប្រចាំ</u> ហើយបង្កើតមូលដ្ឋានគណនាតម្រូវការចំណាយនេះ ឱ្យបានច្បាស់លាស់*។

ចំណាយជាប្រចាំ គឺជាចំណាយដែលមានតម្រូវការជាប្រចាំជារៀងរាល់ឆ្នាំ ដែលរួមមាន៖ ចំណាយលើសម្ភារផ្គត់ផ្គង់ និងថែទាំជាប្រចាំ (ដូចជា៖ សម្ភារផ្គត់ផ្គង់ ថែទាំតូចតាចសម្រាប់ថែទាំអគារ ប្រាសាទ ផ្លូវថ្នល់ ស្ពាន លូ ប្រព័ន្ធធារាសាស្ត្រ រថយន្ត និងឧបករណ៍ប្រើប្រាស់ផ្សេងៗ) និងសម្ភារផ្គត់ផ្គង់រដ្ឋបាលជាប្រចាំ (ដូចជា សម្ភារ ការិយាល័យ

ការបោះពុម្ព ការទិញឯកសារ សម្ភារបរិក្ខារប្រើប្រាស់ជាប្រចាំ ស្បៀងអាហារ និងឯកសណ្ឋាន សម្រាប់ក្រសួង-ស្ថាប័នមួយចំនួនដែលត្រូវការប្រើប្រាស់ជាប្រចាំ ព្រមទាំងចំណាយលើអគ្គិសនី ទឹក ប្រេងឥន្ធនៈ និងទូរស័ព្ទជាដើម)។ ប្រភេទចំណាយនេះ ត្រូវកំណត់ឱ្យបានច្បាស់លាស់ និងបង្កើតមូលដ្ឋានគណនាឱ្យបានត្រឹមត្រូវ និងសមស្រប ទៅតាមតម្រូវការជាក់ស្តែង ព្រមទាំងវិភាជទៅតាមអង្គភាពថវិកា នាយកដ្ឋាន ឬអង្គភាពជំនាញដែលអនុវត្តផ្ទាល់។

- *<u>កំណត់ចំណាយមិនប្រចាំ</u> ដោយត្រូវមានគម្រោងច្បាស់លាស់បញ្ជាក់ពីតម្រូវការ និងប្រសិទ្ធភាពនៃការប្រើប្រាស់ចំណាយមិនប្រចាំនេះ ព្រមទាំងមូលដ្ឋានគណនាតម្រូវការចំណាយនេះឱ្យច្បាស់លាស់។* ចំណាយមិនជាប្រចាំ គឺជាចំណាយដែលមិនត្រូវការចំណាយជារៀងរាល់ឆ្នាំ រួមមានៈ ចំណាយបំពាក់ឧបករណ៍ សម្ភារដឹកជញ្ជូន សម្ភារបរិក្ខារបច្ចេកទេស គ្រឿងសង្ហារិម និងឧបករណ៍សម្ភារប្រើប្រាស់ផ្សេងៗ ដែលជាចំណាយមិនត្រូវទិញប្រចាំឆ្នាំ ព្រមទាំងចំណាយសម្រាប់ការជួសជុល បោះពុម្ព កិច្ចប្រជុំ សិក្ខាសាលា និងបេសកកម្មមួយចំនួនដែលមិនមែនជាសកម្មភាពជាប្រចាំឆ្នាំ។ ប្រភេទចំណាយនេះ ត្រូវមានគម្រោង និងពេលអនុវត្តច្បាស់លាស់សម្រាប់ទាំងពេលខ្លី និងពេលមធ្យម ព្រមទាំងមានមូលដ្ឋានគណនាតម្រូវការចំណាយត្រឹមត្រូវទៅតាមតម្រូវការជាក់ស្តែង។

- **ក្រសួង-ស្ថាប័ននៅរដ្ឋបាលកណ្តាល៖** ត្រូវគ្រោងថវិកាទៅតាមទំហំពិតានចំណាយគោលឆ្នាំ ២០២៤ ប៉ុន្តែ*កញ្ចប់ថវិកាតាមពិតានចំណាយគោលនេះ នឹងមិនទទួលបានជាស្វ័យប្រវត្តិនោះទេ*។ រាល់ការគ្រោងចំណាយទាំងអស់ ត្រូវភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធ រួមមានការសិក្សា វិភាគ វាយតម្លៃ និងអំណះអំណាងត្រឹមត្រូវ និងច្បាស់លាស់ ទើបអាចដាក់ជាកម្មវត្ថុនៃការពិចារណា និងពិភាក្សាចរចានៅពេលរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំបាន។ នេះមានន័យថា ពិតានចំណាយគោល គឺនៅតែជាកម្មវត្ថុសម្រាប់ការពិភាក្សានៅពេលចរចាថវិកា ដើម្បីបង្កើនប្រសិទ្ធភាពនៃការវិភាជថវិកា ក៏ដូចជាដើម្បីសន្សំសំចៃថវិកាសម្រាប់បំពេញតម្រូវការចំណាយចាំបាច់ថ្មី។

- **មន្ទីរជំនាញរាជធានី-ខេត្តនៃក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត** (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល)៖ ផ្អែកលើទំហំពិតានចំណាយគោលរួមដែលផ្តល់ជូនដល់មន្ទីរជំនាញរាជធានី-ខេត្ត, សម្រាប់ឆ្នាំ ២០២៤ មន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលរាជធានី-ខេត្តពាក់ព័ន្ធ ត្រូវគ្រោងថវិកាចំណាយយ៉ាងច្រើនបំផុតស្មើនឹងកម្រិតអតិបរមានៃទំហំពិតានចំណាយគោល។ ក៏ប៉ុន្តែ *កញ្ចប់ថវិកាតាមពិតានចំណាយគោលនេះ* **នឹងមិនទទួលបាន**ជាស្វ័យប្រវត្តិទេ គឺតម្រូវឱ្យមន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលរាជធានី-ខេត្តពាក់ព័ន្ធ ត្រូវផ្តល់ឯកសារពាក់ព័ន្ធដែលមានការសិក្សា វិភាគ វាយតម្លៃ និងអំណះអំណាងត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់ ព្រោះការគ្រោងចំណាយត្រូវកាត់ចេញមុខចំណាយលើសកម្មភាពការងារដែលត្រូវបានបញ្ចប់ ពិសេសចំណាយមិនប្រចាំ ដើម្បីសន្សំសំចៃសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

- ដោយឡែក **សម្រាប់មុខងារមានភ្ជាប់លក្ខខណ្ឌក្នុងវិស័យអប់រំ** ការគ្រោងកញ្ចប់ថវិកាត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងស្តីពីលក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុសម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុងស្រុកទាំង ១៤ ក្នុងខេត្តបាត់ដំបង សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ។

- **គ្រឹះស្ថានសាធារណៈរដ្ឋបាលនៃក្រសួង-ស្ថាប័ននីមួយៗ ត្រូវបានផ្តល់កញ្ចប់ថវិកាឧបត្ថម្ភធន ប៉ុន្តែកញ្ចប់ឧបត្ថម្ភធនដែលគ្រោងផ្តល់នេះមិនទទួលបានជាស្វ័យប្រវត្តិទេ** គឺតម្រូវឱ្យគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ ត្រូវផ្តល់ការពន្យល់ និងអំណះអំណាងត្រឹមត្រូវ និងច្បាស់លាស់នូវស្ថានភាពចំណូលផ្ទៃក្នុងរបស់គ្រឹះស្ថាន និង

ម្យ៉ាងទៀត ក៏ត្រូវកាត់ចេញនូវទំហំចំណាយសម្រាប់សកម្មភាពដែលត្រូវបានបញ្ចប់ ជាពិសេសចំណាយមិនប្រចាំ ដើម្បីសន្សំសំចៃ ក៏ដូចជាសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់។

- ចំពោះការបន្តអនុវត្តសកម្មភាពការងារកំពុងដំណើរការ ត្រូវគ្រោងចំណាយនៃកម្មវិធីនីមួយៗ ដោយផ្អែកលើបរិមាណធាតុចូលដែលធ្លាប់ប្រើក្នុងឆ្នាំ ២០២២ កន្លងមក និងការប៉ាន់ស្មានអនុវត្តនៅក្នុងឆ្នាំ ២០២៣ នេះ និងដោយផ្អែកលើតម្លៃឯកតាជាក់ស្តែងលើទីផ្សារ ហើយចៀសវាងការបង្កើនបរិមាណធាតុចូលលើសពីតម្រូវការដែលធ្លាប់មាន។ ទន្ទឹមនេះ, ត្រូវគ្រោងថវិកាប្រកបដោយលក្ខណៈត្បិតត្បៀត និងសន្សំសំចៃខ្ពស់ ពិសេសលើមុខសញ្ញាទិញឧបករណ៍ សម្ភារបរិក្ខារទំនើប គ្រឿងសង្ហារិមប្រណិត ការបោះពុម្ពប្រណិត សម្ភារការិយាល័យ ប្រេងឥន្ធនៈ ការទទួលភ្ញៀវអធឹកអធម បេសកកម្មក្នុង និងក្រៅប្រទេស ព្រមទាំងសោហ៊ុយចំណាយជាអចិន្ត្រៃយ៍ ដូចជាសេវាទូរគមនាគមន៍ អគ្គិសនី និងទឹក ជាដើម។ លើសពីនេះ, ត្រូវលុបបំបាត់ការខ្ជះខ្ជាយចំណាយ ឬបំប៉ោង ចំណាយលើការរៀបចំកិច្ចប្រជុំ សិក្ខាសាលាថ្នាក់ជាតិ និងអន្តរជាតិ ការតាំងពិព័រណ៍។ កិច្ចប្រជុំពាក់ព័ន្ធនឹងអាស៊ាន គឺអនុញ្ញាតសម្រាប់តែកិច្ចប្រជុំដែលត្រូវវេន, ចំពោះកិច្ចប្រជុំដែលមិនចំវេនគឺត្រូវសុំគោលការណ៍អនុញ្ញាតពីប្រមុខរាជរដ្ឋាភិបាលជាមុនសិន។ ចំពោះកិច្ចប្រជុំ ឬសិក្ខាសាលា ដែលគ្រោងក្នុងថវិកាត្រូវបង្ហាញពីភាពចាំបាច់ និងភាពសមរម្យនៃការរៀបចំទាំងក្នុងទំហំ និងតម្លៃ។

- ត្រូវពិនិត្យឡើងវិញ និងត្រូវកាត់ចេញនូវមុខចំណាយទាំងឡាយណាដែលមានតម្រូវការសម្រាប់តែអនុវត្តក្នុងឆ្នាំ ២០២៣ ហើយលែងត្រូវការក្នុងឆ្នាំ ២០២៤ ឬសកម្មភាពការងារដែលនឹងត្រូវបញ្ចប់ក្នុងឆ្នាំ ២០២៣។ លើសពីនេះ, ត្រូវកាត់ចេញនូវទំហំចំណាយនៃសកម្មភាពការងារមួយចំនួនដែលត្រូវបានវាយតម្លៃថា លែងមានសារៈសំខាន់ ដូចជា៖ **សកម្មភាពចូលរួមតាំងពិព័រណ៍ពាណិជ្ជកម្ម និងពិព័រណ៍ទេសចរមួយចំនួនដែលលែងមានភាពចាំបាច់។ ក្នុងន័យនេះ, ថវិកាដែលកាត់ចេញពីមុខចំណាយ ឬសកម្មភាពការងារដែលត្រូវបានបញ្ចប់មិនមែនជាកម្មវត្ថុនៃការវិភាជឡើងវិញជាស្វ័យប្រវត្តិនោះទេ លុះត្រាតែមានសកម្មភាពការងារចាំបាច់ថ្មី ឬគោលនយោបាយថ្មីដែលមានការសម្រេចច្បាស់លាស់ពីរាជរដ្ឋាភិបាលជាយថាហេតុ** ដែលត្រូវអនុវត្ត និងដែលត្រូវបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៤-២០២៦ និងមានយុត្តការណ៍អំពីភាពចាំបាច់ និងបន្ទាន់ ព្រមទាំងមានការពន្យល់ និងផ្តល់អំណះអំណាងច្បាស់លាស់ និងត្រឹមត្រូវ ដោយភ្ជាប់មកជាមួយនូវគម្រោងចំណាយលម្អិតច្បាស់លាស់ ទើបចាត់ទុកជាកម្មវត្ថុនៃការត្រួតពិនិត្យ និងពិភាក្សាអំពីលទ្ធភាពថវិកា។

- ចំពោះតម្រូវការចំណាយបន្ថែមលើសពីកញ្ចប់ថវិកា ដែលត្រូវបានកំណត់ជាពិតានចំណាយគោល គឺត្រូវឆ្លងការចរចាកម្រិតថ្នាក់ដឹកនាំក្រសួង ឬក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងស្នើសុំការសម្រេច ឬស្នើសុំការសម្រេចឡើងវិញពីប្រមុខរាជរដ្ឋាភិបាល បន្ទាប់ពីមានឯកសារទស្សនាទាន យុត្តការណ៍ស្តីពីគោលនយោបាយ និងកម្មវិធី ឬមុខសញ្ញាចំណាយ និងតម្លៃច្បាស់លាស់។ *សម្រាប់ក្រសួង-ស្ថាប័ន និង គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានភារកិច្ចប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវរៀបចំដាក់ចេញវិធានការជាក់ស្តែងបន្ថែមសម្រាប់ពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល ព្រោះលទ្ធផល និងការបង្ហាញពីកិច្ចខិតខំក្នុងការប្រមូលចំណូល គឺជាកម្មវត្ថុនៃការរឹតត្បិត ឬការលើកទឹកចិត្តចំណាយ នៅក្នុងដំណាក់កាលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំ។*

- ត្រូវបង្កើនវិមជ្ឈការនៃការផ្ទេរចំណាយរដ្ឋបាលជាប្រចាំ និងសោហ៊ុយបេសកកម្មក្នុង និងក្រៅប្រទេសជាដើម ទៅឱ្យតាមអង្គភាពថវិកាឱ្យបានច្រើនក្នុងកម្រិតអតិបរមា។

- ដើម្បីអនុវត្តផែនការសកម្មភាពនៃយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវរៀបចំជាផែនការសកម្មភាពការងារទៅតាមកម្មវិធី និងលើកសំណើសុំថវិកាក្នុងក្របខ័ណ្ឌនៃកញ្ចប់ថវិការួមប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័ននីមួយៗ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងពិនិត្យ និងវិភាជថវិកាជូនក្រសួង-ស្ថាប័នពាក់ព័ន្ធ តាមលទ្ធភាពថវិកាជាក់ស្តែង។

- ក្រសួង-ស្ថាប័នត្រូវពិនិត្យលទ្ធភាពនៃការផ្ទេរធនធានថវិកាពីកម្មវិធីមួយទៅកម្មវិធីមួយទៀត ឬពីអង្គភាពថវិកាមួយទៅអង្គភាពថវិកាមួយទៀតនៅផ្ទៃក្នុងក្រសួង-ស្ថាប័ននីមួយៗឱ្យអស់លទ្ធភាព ព្រមជាមួយនឹងការថ្លឹងថ្លែងតុល្យភាពនៃការបែងចែកធនធាន និងសិទ្ធិអំណាចទៅតាម និងរវាងអង្គភាពថវិកានីមួយៗ ក្នុងក្របខ័ណ្ឌពិតានកញ្ចប់ថវិកាដែលបានកំណត់ និងត្រូវចៀសវាងការបំប៉ោងចំណាយ ដោយមូលហេតុនៃការអនុវត្តថវិកាកម្មវិធី។

- ជាមួយគ្នានេះដែរ ដើម្បីបង្កើនប្រសិទ្ធភាពចំណាយនៅដំណាក់កាលរៀបចំ និងចរចាថវិកា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានអនុញ្ញាតឱ្យកាត់ចេញនូវថវិកាប្រភេទចំណាយមិនជាប្រចាំផ្ទៃក្នុងក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលរាជធានី-ខេត្ត (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល)។ ទំហំថវិកាដែលនៅសល់ក្នុងក្របខ័ណ្ឌពិតាននេះ អាចជាកម្មវត្ថុនៃការវិភាជសម្រាប់កែលម្អ ឬបង្កើនប្រសិទ្ធភាពនៃកម្មវិធីដែលមានស្រាប់ ឬសម្រាប់កម្មវិធីបម្រើឱ្យគោលនយោបាយថ្មីនៅក្នុងក្រសួង-ស្ថាប័នដដែល ឬទៅក្រសួង-ស្ថាប័នមួយទៀត ឬពីមន្ទីរជំនាញមួយ ទៅមន្ទីរជំនាញមួយទៀតនៃក្រសួង-ស្ថាប័នតែមួយ ក៏ដូចជាពីមន្ទីរនៃរដ្ឋបាលរាជធានី-ខេត្តមួយ ទៅមន្ទីរនៃរដ្ឋបាលរាជធានី-ខេត្តមួយទៀតក្នុងក្របខ័ណ្ឌនៃវិស័យចំណាយតែមួយ។

**គ-ចំណាយមូលធនសម្រាប់គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាថ្នាក់ជាតិ (ជំពូក ២១) និងចំណាយជួសជុល ស្តារ និង ថែទាំផ្លូវថ្នល់ និងធារាសាស្ត្រ (ជំពូក ៦១) ត្រូវបន្តអនុវត្តតាមនីតិវិធី ដែលបាននិងកំពុងអនុវត្តជាធរមាន និងទៅតាមគោលការណ៍សំខាន់ៗ ដូចខាងក្រោម៖**

- ក្រសួងដែលទទួលបានចំណាយវិនិយោគជាទៀងទាត់ រួមមាន៖ ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសុខាភិបាល និងក្រសួងមហាផ្ទៃ ត្រូវធ្វើសមាហរណកម្មគម្រោងចំណាយវិនិយោគជាមួយនឹងគម្រោងចំណាយចរន្តនៅកម្រិតកម្មវិធី និងអនុកម្មវិធី ព្រមទាំងត្រូវរៀបចំបញ្ជីគម្រោងអាទិភាពប្រចាំឆ្នាំឱ្យបានទាន់ពេល ដើម្បីស្នើសុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាល សម្រាប់ជាមូលដ្ឋាននៃការរៀបចំបញ្ជីគម្រោងសង្ខេប ដែលនឹងត្រូវវេចខ្ចប់ជាមួយនឹងចំណាយចរន្តនៅក្នុងសេចក្តីព្រាងច្បាប់ថវិកា។ ចំពោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងការងារ និងបណ្តុះ-បណ្តាលវិជ្ជាជីវៈ និង ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលត្រូវទទួលបានថវិកាជំពូក ២១ សម្រាប់គម្រោងវិនិយោគផ្ទាល់ ក៏ត្រូវចាប់ផ្តើមសាកល្បងធ្វើសមាហរណកម្មគម្រោងចំណាយវិនិយោគជាមួយនឹងគម្រោងចំណាយចរន្ត នៅកម្រិតកម្មវិធី និងអនុកម្មវិធីផងដែរ សម្រាប់ជាមូលដ្ឋានស្នើសុំការពិនិត្យ និងសម្រេចពីប្រមុខរាជរដ្ឋាភិបាល។ ចំពោះការកំណត់អាទិភាព និងជ្រើសរើសគម្រោងដែលក្រសួងនីមួយៗបានស្នើឡើង គឺជាកម្មវត្ថុនៃការពិនិត្យពិភាក្សា តាមយន្តការគណៈកម្មការ ឬក្រុមការងារអន្តរក្រសួង ដោយផ្អែកទៅតាមអាទិភាពគោល-នយោបាយរបស់រាជរដ្ឋាភិបាល និងគោលការណ៍កំណត់អាទិភាពគម្រោងដែលមានចែងនៅក្នុងសារាចរនេះ។

- សម្រាប់ក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដើម្បីទទួលបានថវិកាពីកញ្ចប់ថវិកាមិនទាន់បែងចែករបស់រាជរដ្ឋាភិបាល ត្រូវសិក្សានិងលើកគម្រោងក្នុងកម្រិតទំហំថវិកាសមស្រប ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យ

និងរៀបចំអាទិភាវូបនីយកម្មគម្រោង គោរពស្នើសុំការសម្រេចដ៏ខ្ពង់ខ្ពស់របស់ប្រមុខរាជរដ្ឋាភិបាល តាមលទ្ធភាពថវិកាប្រចាំឆ្នាំ។ គម្រោងវិនិយោគដែលអាចស្នើឡើងដើម្បីពិភាក្សា ត្រូវបំពេញតាមគោលការណ៍ និងលក្ខខណ្ឌតម្រូវដែលមានកំណត់នៅក្នុងអនុក្រឹត្យស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

- ការគ្រោងចំណាយវិនិយោគសម្រាប់គម្រោងសាងសង់ ស្តារ ជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពាន ប្រព័ន្ធធារាសាស្ត្រ អប់រំ សុខាភិបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ត្រូវផ្អែកលើគោលការណ៍កំណត់អាទិភាព ដូចខាងក្រោម៖

- *វិស័យផ្លូវថ្នល់*
  - ✓ **អាទិភាពទី១៖** ជួសជុល ស្តារ និងថែទាំផ្លូវជាតិគ្រប់ប្រភេទ ដើម្បីរក្សាសមិទ្ធផល ធានាចីរភាពនៃប្រព័ន្ធគមនាគមន៍ និងចរាចរ **និងទ្រទ្រង់ជម្រើមសេដ្ឋកិច្ច។**
  - ✓ **អាទិភាពទី២៖** ជួសជុល ស្តារ និងថែទាំផ្លូវខេត្ត និងផ្លូវជនបទសំខាន់ៗ ដែលមានលក្ខណៈជាឆ្អឹងខ្នងនៃប្រព័ន្ធគមនាគមន៍ ដែលបម្រើឱ្យការដឹកជញ្ជូន និងចរាចរ នៅកម្រិតមូលដ្ឋាន **កម្រិតតំបន់** និង កម្រិតជាតិ។
  - ✓ **អាទិភាពទី៣៖** គម្រោងថ្មីដែលមានការសម្រេចច្បាស់លាស់ពី**សម្តេចតេជោនាយករដ្ឋមន្ត្រី។**
  - ✓ **អាទិភាពទី៤៖** *គម្រោងពហុឆ្នាំដែលត្រូវសាងសង់បញ្ចប់ ឬគម្រោងដែលមានចរិតពហុឆ្នាំនិងមានប្រសិទ្ធភាពខ្ពស់* រួមទាំងគម្រោង *ខូចខាតដែលបណ្តាលមកពីទឹកជំនន់* ។
  - ✓ **អាទិភាពទី៥៖** គម្រោងថ្មីដែលមានការសិក្សាច្បាស់លាស់ និងមានសក្តានុពល សេដ្ឋកិច្ចសង្គម និងនយោបាយខ្ពស់ រួមទាំងគម្រោងពាក់ព័ន្ធនឹងការរក្សាអធិបតេយ្យភាព និងអភិវឌ្ឍន៍តាមតំបន់ព្រំដែន។
- *វិស័យធារាសាស្ត្រ*
  - ✓ **អាទិភាពទី១៖** ជួសជុល ស្តារ និងថែទាំប្រព័ន្ធធារាសាស្ត្រគ្រប់ប្រភេទ ជាពិសេស ប្រព័ន្ធធារាសាស្ត្រដែលបានស្តាបនារួចដោយថវិកាជាតិ ឬថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ។
  - ✓ **អាទិភាពទី២៖** ពង្រីកបន្ថែមសក្តានុពលប្រព័ន្ធធារាសាស្ត្រធំៗដែលបានស្តាបនារួចដោយថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍនានា។
  - ✓ **អាទិភាពទី៣៖** ស្តាបនាគម្រោងដែលមានចរិតពហុឆ្នាំដែលត្រូវសាងសង់បន្ត ឬបញ្ចប់ដើម្បីឱ្យក្លាយជាប្រព័ន្ធធារាសាស្ត្រដែលមានលក្ខណៈពេញលេញ និងស្តារឡើងវិញគម្រោង *ខូចខាតដែលបណ្តាលមកពីទឹកជំនន់* ឬគ្រោះធម្មជាតិផ្សេងៗ។
  - ✓ **អាទិភាពទី៤៖** គម្រោងថ្មីដែលមានការសិក្សាច្បាស់លាស់ និងមានសក្តានុពលសេដ្ឋកិច្ចសង្គម និងនយោបាយខ្ពស់។
  - ✓ **អាទិភាពទី៥៖** គម្រោងដែលពាក់ព័ន្ធនឹងការស្តាបនាសំណង់ការពារបាក់ច្រាំងនៅតាមដងទន្លេ ស្ទឹង ព្រែក។
- *វិស័យអប់រំ*
  - ✓ **អាទិភាពទី១៖** គម្រោងថ្មីដែលមានការសម្រេចច្បាស់លាស់ពី**សម្តេចតេជោនាយករដ្ឋមន្ត្រី។**

✓ **អាទិភាពទី២៖** គម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធអប់រំនៅតាមសាលាបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា, សាលាបណ្តុះបណ្តាលគរុកោសល្យ វិក្រឹតការ។

✓ **អាទិភាពទី៣៖** គម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធអប់រំ យុវជន និងកីឡា នៅតាមបណ្តារាជធានី-ខេត្តនានា ក្នុងព្រះរាជាណាចក្រកម្ពុជា។

- *<u>វិស័យសុខាភិបាល</u>*

✓ **អាទិភាពទី១៖** គម្រោងថ្មីដែលមានការសម្រេចច្បាស់លាស់ពីសម្តេចតេជោនាយករដ្ឋមន្ត្រី។

✓ **អាទិភាពទី២៖** ផ្តល់អាទិភាពដល់គម្រោងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសុខាភិបាល និងប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដើម្បីលើកកម្ពស់គុណភាព និងកែលម្អសេវាសុខភាពសាធារណៈ មានដូចជា៖ មន្ទីរពេទ្យបង្អែក, អគារពិនិត្យសម្រាកព្យាបាលជំងឺ, មណ្ឌលសុខភាព, ប៉ុស្តិ៍សុខភាព, ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ព្រមទាំងឧបករណ៍វេជ្ជសាស្ត្រ និងសម្ភារបរិក្ខារពេទ្យនានា។

- *<u>វិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ</u>*

✓ **អាទិភាពទី១៖** គម្រោងស្ថាបនាប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់។

✓ **អាទិភាពទី២៖** គម្រោងស្ថាបនាប៉ុស្តិ៍នគរបាលការពារព្រំដែន។

✓ **អាទិភាពទី៣៖** គម្រោងជួសជុលនិងស្ថាបនាពន្ធនាគារ។

✓ **អាទិភាពទី៤៖** គម្រោងអាទិភាពផ្សេងទៀតដែលមានការសម្រេចច្បាស់លាស់ពីសម្តេចតេជោនាយករដ្ឋមន្ត្រី។

**ឃ-ចំណាយមូលធន/វិនិយោគដោយហិរញ្ញប្បទានសហប្រតិបត្តិការដោយដៃគូអភិវឌ្ឍ៖** ក្រសួង-ស្ថាប័នចំនួន ៩ ដែលនឹងទទួលបាននូវការវិភាជថវិកាជំពូក ២១ (គម្រោងវិនិយោគផ្ទាល់) និងថវិកាជំពូក ៦១ (ការងារជួសជុល និងថែទាំ) ព្រមទាំងក្រសួង-ស្ថាប័នដទៃទៀត ដែលបាននិងកំពុងទទួលបានហិរញ្ញប្បទានសហប្រតិបត្តិការ ឬគ្រោងនឹងទទួលបានហិរញ្ញប្បទាន ស្របតាមកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល (២០២៤-២០២៦) ត្រូវគ្រោងឱ្យបានត្រឹមត្រូវទៅតាមកិច្ចព្រមព្រៀង ឬអនុស្សារណៈនៃការយោគយល់គ្នា ឬការសន្យាតាមរយៈយន្តការផ្សេងៗ។

៣៤-**ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ៖** ក្នុងគោលបំណងលើកកម្ពស់គុណភាពនៃការរៀបចំផែនការលទ្ធកម្ម និងអនុលោមភាពនៃការអនុវត្តផែនការលទ្ធកម្មប្រចាំឆ្នាំ ដើម្បីធានាឱ្យការរៀបចំថវិកាប្រចាំឆ្នាំកាន់តែមានប្រសិទ្ធភាព **ហើយជាពិសេសធានាឱ្យថវិកាអាចអនុវត្តបានភ្លាមចាប់ពីខែមករានៃឆ្នាំសារពើពន្ធ** គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលរាជធានី-ខេត្ត (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំសម្រាប់មុខចំណាយដែលត្រូវអនុវត្តនីតិវិធីលទ្ធកម្ម ដោយផ្អែកលើកញ្ចប់ថវិកាដែលគ្រោងស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដូច្នេះ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំង រដ្ឋបាលរាជធានី-ខេត្ត (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវភ្ជាប់ផែនការលទ្ធកម្មមកជាមួយនឹងសំណើគម្រោងថវិកាឆ្នាំ ២០២៤ របស់ខ្លួនចំនួន**ពីរច្បាប់** (១ ច្បាប់បញ្ជូនទៅអគ្គនាយកដ្ឋានថវិកា និង ១ ច្បាប់ទៀតបញ្ជូនទៅអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) សម្រាប់ការប្រជុំពិភាក្សាកម្រិត

បច្ចេកទេស និងការចរចាកញ្ចប់ថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង។ គោលការណ៍ និងនីតិវិធីនៃការរៀបចំផែនការលទ្ធកម្ម ត្រូវអនុលោមតាមបទប្បញ្ញត្តិដូចមានចែងក្នុងប្រកាសលេខ ៨៥១ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៧ ស្តីពីការរៀបចំផែនការលទ្ធកម្ម។

បន្ទាប់មក ផ្អែកលើស្មារតី និងលទ្ធផលនៃការចរចាកញ្ចប់ថវិកា ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលរាជធានី-ខេត្ត (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវកែសម្រួលសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំឱ្យមានសង្គតិភាពជាមួយនឹងកញ្ចប់ថវិកាដែលទទួលបាននៅក្នុងកិច្ចប្រជុំចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង រួចបញ្ជូនសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំដែលបានកែសម្រួលរួចនេះ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **យ៉ាងយូរបំផុតត្រឹមសប្តាហ៍ទី ៣ ខែ វិច្ឆិកា** ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានពេលវេលាគ្រប់គ្រាន់សម្រាប់ពិនិត្យ និងអនុម័តឱ្យបានមុនថ្ងៃទី ៣១ ខែ ធ្នូ មុនឆ្នាំអនុវត្តថវិកា។

**៣៥-ការរៀបចំផែនការឥណទានវត្ថុទេយ្យបុរេប្រទានៈ** ត្រូវធ្វើឡើងដំណាលគ្នានឹងការរៀបចំគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំ សម្រាប់ពិនិត្យនិងពិភាក្សាក្នុងកិច្ចប្រជុំការពារគម្រោងថវិកាប្រចាំឆ្នាំ។ ក្នុងអំឡុងពេលប្រជុំការពារគម្រោងថវិកា មិនតម្រូវឱ្យពិនិត្យមើលលម្អិតលើតារាងឧបសម្ព័ន្ធវត្ថុទេយ្យបុរេប្រទានទេ ប៉ុន្តែក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលរាជធានី-ខេត្ត (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវធានាថាឥណទានថវិកាដែលត្រូវយកមករៀបចំតារាងឧបសម្ព័ន្ធវត្ថុទេយ្យបុរេប្រទាន មិនត្រូវត្រួតគ្នានឹងឥណទានថវិកាដែលត្រូវបានគ្រោងទុកអនុវត្តកិច្ចលទ្ធកម្មសាធារណៈ តាមនីតិវិធីទូទាត់ត្រង់ និងនីតិវិធីចំណាយផ្សេងទៀតទេ។

**៣៦-ការផ្តល់របាយការណ៍សមិទ្ធកម្មៈ** ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ដែលអនុវត្តថវិកាកម្មវិធី ត្រូវតែផ្តល់របាយការណ៍សមិទ្ធកម្មនៃការអនុវត្តថវិកាកម្មវិធីឆ្នាំ ២០២២ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) ដើម្បីត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្ត ហើយក៏ជាកម្មវត្ថុសម្រាប់ការលើកទឹកចិត្ត ឬការកាត់បន្ថយគម្រោងចំណាយឆ្នាំ ២០២៤ ផងដែរ។ *នៅពេលពិភាក្សា និងចរចាថវិកា ក្រសួង-ស្ថាប័ននីមួយៗត្រូវតែរៀបចំជាបទបង្ហាញអំពីរបាយការណ៍សមិទ្ធកម្មឆ្នាំ ២០២២ របាយការណ៍សមិទ្ធកម្មពាក់កណ្តាលឆ្នាំ ២០២៣ និងការគ្រោងលទ្ធផលរំពឹងទុកសម្រាប់ឆ្នាំ ២០២៤។*

ទន្ទឹមគ្នានេះ, សម្រាប់ការអនុវត្តសាកល្បងថវិកាសមិទ្ធកម្ម និងស្របតាមគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាសមិទ្ធកម្ម, គ្រប់ក្រសួង-ស្ថាប័ន ត្រូវចាប់ផ្តើមរៀបចំរបាយការណ៍ចំណាយបន្ទុកបុគ្គលិកដោយបែងចែកទៅតាមកម្មវិធីនីមួយៗ ទៅតាមទម្រង់តារាងលេខ ១១ ដូចមានភ្ជាប់ជូន ដោយយកឆ្នាំនៃការអនុវត្តថវិកា ១ ឆ្នាំមុន (ឆ្នាំ N-1) ជាមូលដ្ឋានសម្រាប់ការរៀបចំ។

**៣៧-ការបម្រែបម្រួលនៃការគ្រោងថវិកាតាមកម្មវិធីៈ** ផ្អែកលើមូលដ្ឋាននៃច្បាប់ថវិកាឆ្នាំ ២០២៣ ដែលកំពុងអនុវត្ត, ក្នុងការរៀបចំថវិកាឆ្នាំ ២០២៤, ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ អាចពិនិត្យផងដែរទៅដល់បម្រែបម្រួលនៃថវិកាក្នុងអំឡុងពេលអនុវត្តដែលទាក់ទងទៅនឹងបណ្តាមូលហេតុដូចខាងក្រោមៈ

- ចលនាឥណទានដែលបានធ្វើឡើងក្នុងឆ្នាំកំពុងអនុវត្ត ដូចជាការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ឬពីជំពូកមួយទៅជំពូកមួយទៀតផ្ទៃក្នុង ឬពីកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពមួយទៅកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពមួយទៀត ដែលធ្វើឱ្យការបែងចែកឥណទានដើមនៃក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ មានការប្រែប្រួល,
- ការផ្ទេរឥណទានថវិកាបន្ថែម សម្រាប់ផលប្រយោជន៍របស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ។

៣៨-អនុវត្តតាមប្រកាសលេខ ៣៥៤ សហវ.ប្រក ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០២២ **ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិការគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង**, ក្រសួង-ស្ថាប័នចំនួន ៤ រួមមានៈ **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងមហាផ្ទៃ (ផ្នែកសន្តិសុខសាធារណៈ), ក្រសួងសុខាភិបាល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** ត្រូវបានជ្រើសរើសឱ្យអនុវត្តសាកល្បងនូវគោលការណ៍ណែនាំនេះ ដោយតម្រូវឱ្យក្រសួងទាំង ៤ ត្រូវរៀបចំនូវឯកសារគ្រោងចំណាយមួយទៀត ជាការសាកល្បងផ្លាស់ប្តូរមុខចំណាយជាសារវន្តមួយចំនួនដែលមានចរិតជាចំណាយមូលធន ពីការគ្រោងក្នុងជំពូក ៦០ និងជំពូក ៦១ នៃថវិកាចំណាយចរន្តទៅគ្រោងក្នុងជំពូក ២០, ជំពូក ២១ ឬជំពូក ២៣ នៃចំណាយមូលធនវិញ ស្របតាមវិធីសាស្ត្រដែលមានចែងលម្អិតក្នុងគោលការណ៍ណែនាំនេះ។

៣៩-ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវពង្រឹងតួនាទីក្រុមការងារថវិការបស់ខ្លួន និងត្រូវផ្តល់កិច្ចសហការគ្នាទៅវិញទៅមកជាប្រចាំឱ្យបានពេញលេញក្នុងកម្រិតបច្ចេកទេស ជាមួយក្រុមការងារថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) សំដៅបង្កើនប្រសិទ្ធភាព និងភាពទាន់ពេលវេលានៃការរៀបចំថវិកាប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័ននីមួយៗ។

## ៤.៣- កាលវិភាគនៃការរៀបចំគម្រោងចំណូល-ចំណាយថវិកាឆ្នាំ ២០២៤

៤០-រាជរដ្ឋាភិបាលមានកាតព្វកិច្ចរៀបចំឱ្យបានទាន់ពេលវេលានូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤។ នៅក្នុងកិច្ចដំណើរការនេះ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការរបស់រាជរដ្ឋាភិបាល ត្រូវដឹកនាំការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៤ នេះ ដើម្បីសេចក្តីព្រាងច្បាប់នេះ និងសំណុំឯកសារពាក់ព័ន្ធ ត្រូវបានអនុម័ត និងប្រកាសឱ្យប្រើដោយព្រះរាជក្រម ឱ្យបានចប់សព្វគ្រប់យ៉ាងយូរត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ស្របតាម មាត្រា ៥១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុថ្មី។ ដូចនេះ, **ឯកសារផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៤-២០២៦ និងគម្រោងចំណូល-ចំណាយថវិកាឆ្នាំ ២០២៤** ដែលក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ បានដាក់ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាមូលដ្ឋានចាំបាច់មិនអាចខ្វះបានសម្រាប់**ការចរចាថវិកាទាំងកម្រិតបច្ចេកទេស** និង**ការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង** ដើម្បីធ្វើយុត្តិកម្មកញ្ចប់ថវិការបស់ខ្លួន។

ក្នុងន័យនេះ, ក្នុងករណីដែលក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញរាជធានី-ខេត្ត គ្រឹះស្ថានសាធារណៈរដ្ឋបាល ឬរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធណាមួយមិនបានបំពេញ និងផ្តល់ព័ត៌មានគ្រប់គ្រាន់ទៅតាមគោលការណ៍ និងតារាងគំរូ ដែលភ្ជាប់ជាមួយសារាចរនេះ នោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវជូនព័ត៌មានទៅក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនោះឱ្យបានទាន់ពេលវេលា ដើម្បីធ្វើការបំពេញបន្ថែម ហើយប្រសិនបើនៅតែមិនអាចបំពេញបានទេនោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិគ្រប់គ្រាន់ក្នុងការយក

មូលដ្ឋាននៃកម្រិតពិតានចំណាយគោល ដោយប្រើគោលការណ៍កំណត់កញ្ចប់តាមជំពូកខាងលើ សម្រាប់កំណត់គម្រោងថវិការបស់ក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញរាជធានី-ខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនោះ ដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤ ឱ្យបានទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយ។

**៥- សេចក្តីសន្និដ្ឋាន**

៤១-ខ្លឹមសារនៃសារាចរនេះ បានកំណត់ក្របខ័ណ្ឌ និងវិធានការ ព្រមទាំងគោលការណ៍ និងបច្ចេកទេសក្នុងការគ្រោងចំណូល និងចំណាយចាំបាច់សម្រាប់ជាមូលដ្ឋានដល់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ រៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួន សំដៅធានាសម្រេចឱ្យបានជោគជ័យនូវគោលបំណងគោលនយោបាយ និងកម្មវិធី ដើម្បីរួមចំណែកសម្រេចឱ្យបានគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនេះ, ក្នុងបរិការណ៍នៃសេដ្ឋកិច្ចកម្ពុជាបាននិងកំពុងហ៊ុមព័ទ្ធដោយហានិភ័យ និងភាពមិនប្រាកដប្រជាខ្ពស់ ដោយសារការកើនឡើងនូវភាពតានតឹងនៃភូមិសាស្ត្រនយោបាយ, ការថមថយសេដ្ឋកិច្ចសកល ការរឹតបន្តឹងយូរជាងការរំពឹងទុកនៃគោលនយោបាយរូបិយវត្ថុរបស់សហរដ្ឋអាម៉េរិក និងការឡើងថ្លៃនៃរូបិយប័ណ្ណដុល្លារអាម៉េរិក ជាដើម, រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងវិធានការចាំបាច់ និងបន្ទាន់នានា ក្នុងគោលបំណងដើម្បីរក្សាលំនឹង និងជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្ន តាមរយៈការបន្តជំរុញការស្តារ និងពង្រឹងចន្ទល់កំណើនសេដ្ឋកិច្ចឱ្យរស់និងត្រឡប់ទៅកំណើនសក្តានុពល, ចាប់យកឱ្យបាននូវកាលានុវត្តភាពថ្មីៗ ដែលកំពុងលេចឡើង និងកសាងភាពធន់សង្គម-សេដ្ឋកិច្ច។

៤២-ទោះជាយ៉ាងណាក្តី, ដើម្បីឱ្យគោលដៅទាំងឡាយដែលបានដាក់ចេញក្នុងសារាចរនេះ អាចអនុវត្តសម្រេចបានជោគជ័យ ថ្នាក់ដឹកនាំគ្រប់ក្រសួង-ស្ថាប័ន និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ចាំបាច់ត្រូវខិតខំថែមទៀតប្រកបដោយឆន្ទៈប្តូរផ្តាច់ ជាពិសេសត្រូវតែផ្លាស់ប្តូរឥរិយាបទនិងផ្នត់គំនិតក្នុងការរៀបចំថវិកា ដោយខិតខំគោរពឱ្យបានខ្ជាប់ខ្ជួនតាមក្របខ័ណ្ឌ និងបណ្តាវិធានការ ព្រមទាំងគោលការណ៍ និងបច្ចេកទេសទាំងឡាយ ទាំងផ្នែកចំណូល និងផ្នែកចំណាយ ដែលកំណត់ដោយសារាចរនេះ។ ទន្ទឹមនេះ, គ្រប់ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវបន្តជំរុញការលើកកម្ពស់អភិបាលកិច្ចល្អក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ ដើម្បីមិនត្រឹមតែអាចបង្កើនសក្តានុពលនៃតួនាទីរបស់ថវិកា ឱ្យទៅជាឧបករណ៍សម្រាប់អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលប៉ុណ្ណោះទេ ថែមទាំងអាចធ្វើជាចន្ទល់ដ៏រឹងមាំសម្រាប់ទ្រទ្រង់ដល់ការដ្ឋានកម្មវិធីកែទម្រង់ដទៃទៀត ដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋផងដែរ។

៤៣-ពេលទទួលបានសារាចរនេះ គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវរៀបចំជាការប្រញាប់នូវ *ផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ ២០២៤-២០២៦ ដែលមានវិសាលភាពគ្របដណ្តប់ទាំងផែនការយុទ្ធសាស្ត្រថវិការបស់មន្ទីរជំនាញរាជធានី-ខេត្ត របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ), និងគម្រោងចំណូល-ចំណាយថវិការបស់ខ្លួនសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤* ទៅតាមតារាងគំរូដែលភ្ជាប់មកជាមួយនេះ និងផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) ចំនួនពីរច្បាប់យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០២៣ ជាកំហិត ដើម្បីមានពេល

គ្រប់គ្រាន់សម្រាប់ការពិភាក្សាថវិកាកម្រិតបច្ចេកទេស និងបូកសរុប ហើយអាចចាប់ផ្តើមដំណើរការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង-ស្ថាប័នទាន់ពេលវេលាកំណត់។ ក្នុងការអនុវត្តសារាចរនេះ, ប្រសិនបើក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា)។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
 "ដើម្បីជូនជ្រាប"
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-រាជកិច្ច "ដើម្បីចុះផ្សាយ"
-គ្រប់ក្រសួង-ស្ថាប័ន
-គ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល
-គ្រប់អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត
-គ្រប់មន្ទីរជំនាញរាជធានី-ខេត្ត
-រដ្ឋបាលក្រុង-ស្រុកទាំង ១៤ នៃខេត្តបាត់ដំបង
 "ដើម្បីមុខការ"
-ឯកសារ-កាលប្បវត្តិ